ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២១

# របាយការណ៍ប្រឹក្សា

# ស្តីអំពីសកម្មភាពនានាពាក់ព័ន្ធនឹងជនគ្រោះរបស់ អ.វ.ត.ក នៅអំឡុងដំណាក់កាលដែលនៅសេសសល់

សហចៅក្រមរបាយការណ៍ស្តីអំពីមុខងារ
ដែលនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ

ចៅក្រម យូរ ឧត្តរា
ចៅក្រម Claudia FENZ

អង្គជំនុំជម្រះវិសាមញ្ញក្នុង
តុលាការកម្ពុជា

# មាតិកា


សារលិខិតពីប្រធានរដ្ឋបាលស្ដីទី និងអនុប្រធានរដ្ឋបាល ៤

សារលិខិតរបស់សហចៅក្រមរបាយការណ៍ ៦

ប្រវត្តិរូបរបស់សហចៅក្រមរបាយការណ៍ ៨

សាវតារនិងប្រវត្តិ ១០

សកម្មភាពពាក់ព័ន្ធនឹងជនរងគ្រោះ នៅតុលាការព្រហ្មទណ្ឌដែលមានចរិតលក្ខណៈអន្តរជាតូបនីយកម្ម ក្នុងអំឡុងដំណាក់កាលដែលនៅសេសសល់ ១៣

ការវិភាគទស្សនៈ ២០

ការពិភាក្សាអំពីសំណើ ២៥

អនុសាសន៍សម្រាប់ដំណើរការឆ្ពោះទៅមុខ ២៩

ឧបសម្ព័ន្ធ ១
កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិស្តីពី អ.វ.ត.ក ៣៣

ឧបសម្ព័ន្ធ ២
ការចូលរួមចំណែកជាគំនិត ៣៨

ដេវីដ សេហ្វើ (David Scheffer)
មជ្ឈមណ្ឌលឯកសារកម្ពុជា
ជី អាយ ស្សិត (GIZ)
ហេឡេន ចាវីស (Helen Javis)
អង្គការក្តីករុណា
សាកលវិទ្យាល័យឡាត្រូប (La Trobe)
សហមេធាវីនាំមុខ (តំណាងដើមបណ្តឹងរដ្ឋប្បវេណី)
មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់
ម៉ារី វិលម៉ិត (Marie Wilmet)
ណាថាន ជេ. ឆាន (Nathan J. Chan)
រីដ្រេស (REDRESS)
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
សឹម សុរិយ៉ា
អង្គការចិត្តសង្គម អន្តរវប្បធម៌
សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
អង្គភាពគាំពារជនរងគ្រោះ (អ.វ.ត.ក)
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (អ.វ.ត.ក)
អង្គការនារីដើម្បីសន្តិភាព (Women Peace Makers)
អង្គការយុវសន្តិភាព (Youth for Peace)
អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)

# សារលិខិតពីប្រធានរដ្ឋបាលស្ដីទី និងអនុប្រធានរដ្ឋបាល

## ដោយត្រូវយកសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះនៃរបបខ្មែរក្រហមមកពិចារណាជាការចំបាច់

អាណត្តិថ្មីនៃការងារនៅសេសសល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្ដល់ឱកាសពិសេសមួយក្នុងការបន្តការងារដ៏មានសារៈសំខាន់អំពីការទទួលស្គាល់នូវការឈឺចាប់របស់ជនរងគ្រោះនៃរបបខ្មែរក្រហម ដើម្បីចូលរួមចំណែកដ៏មានសារៈសំខាន់ដល់ការផ្សះផ្សាដែលត្រូវបានធានា បន្ទាប់ពីបានឆ្លងកាត់សម័យកាលវិនាសកម្មនេះ និងដើម្បីបង្កើនការចងចាំអំពីការឈឺចាប់ដែលពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រជាពិសេសចំពោះមនុស្សជំនាន់ក្រោយពីរបបខ្មែរក្រហម។

អនុលោមតាមស្មារតីនេះ កាលពីឆ្នាំកន្លងទៅ យើងខ្ញុំបានស្នើសុំដំបូន្មានពី សហចៅក្រមរបាយការណ៍ស្ដីពីមុខងារនៅសេសសល់ពាក់ព័ន្ធនឹងជនរងគ្រោះ គឺលោកចៅក្រម យូរ ឧត្តរា និងលោកស្រីចៅក្រម Claudia FENZ។ កាលពីខែកក្កដា ឆ្នាំ២០២១ យើងបានស្នើសុំអនុសាសន៍ពីសហចៅក្រមទាំងពីររូប ស្ដីពីលទ្ធភាពនៃវិធានការនានាដែលសមស្រប និងប្រកបដោយអត្ថន័យ ចំពោះជនរងគ្រោះនៃរបបខ្មែរក្រហម។

សហចៅក្រមរបាយការណ៍បានជួបប្រជុំយ៉ាងទូលំទូលាយ និងយ៉ាងសកម្មជាមួយដៃគូពាក់ព័ន្ធរបស់ អ.វ.ត.ក នៅក្នុងដំណើរការងាររបស់ពួកគាត់ ហើយយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគីនានាដែលបានចំណាយពេលចែករំលែកមតិយោបល់ និងសំណើនានារបស់ខ្លួនមកយើងខ្ញុំ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះអនុសាសន៍នានាដែលសហចៅក្រមរបាយការណ៍ បានដាក់បង្ហាញមកយើងខ្ញុំកាលពីខែធ្នូ ឆ្នាំ២០២១ ជាទម្រង់របាយការណ៍ផ្ដល់យោបល់ដាក់ក្នុងស្រោមសំបុត្រ។

អនុសាសន៍នានានៅក្នុងរបាយការណ៍ផ្ដល់យោបល់ និងមតិត្រឡប់ជាវិជ្ជមានជាច្រើនដែលយើងខ្ញុំបានទទួល ក្នុងអំឡុងពេលប្រជុំពិគ្រោះយោបល់របស់សហចៅក្រមរបាយការណ៍ បានបង្កើនការតាំងចិត្តរបស់យើង ក្នុងការកំណត់ជាវិធីសមស្របមួយឆ្ពោះទៅមុខរួមគ្នា ដោយត្រូវយកសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះនៃរបបខ្មែរក្រហមមកពិចារណាជាការចំបាច់។ យើងខ្ញុំជឿជាក់ថា តាមរយៈពេលជួបទាក់ទងដោយផ្ទាល់ និងការធ្វើសំយោគគ្នា អង្គជំនុំជម្រះវិសាមញ្ញអាចបង្កើតបាននូវគំនិតផ្ដួចផ្ដើមនានាប្រកបដោយអត្ថន័យ និងចីរភាព។

សិក្ខាសាលាស្ដីពីជនរងគ្រោះនៅខែឧសភា ឆ្នាំ២០២២ បង្ហាញនូវជំហានបែបបរិយាប័ន្នថែមទៀត ក្នុងការរៀបចំសកម្មភាពផ្សព្វផ្សាយរបស់ អ.វ.ត.ក នៅក្នុងរយៈពេលបីឆ្នាំដំបូងនៃអាណត្តិការងារនៅសេសសល់



**ឯ.ឧ ក្រាញ់ តូនី**

**ប្រធានរដ្ឋបាលស្ដីទី**



**លោក Knut ROSANDHAUG**

**អនុប្រធានរដ្ឋបាល**

**យើងខ្ញុំជឿជាក់ថា តាមរយៈពេលជួបទាក់ទងដោយផ្ទាល់ និងការធ្វើសំយោគគ្នា អង្គជំនុំជម្រះវិសាមញ្ញអាចបង្កើតបាននូវគំនិតផ្ដួចផ្ដើមនានាប្រកបដោយអត្ថន័យ និងចីរភាព។**

របស់ខ្លួន។ យើងខ្ញុំសូមជំរុញយ៉ាងខ្លាំងក្លាឱ្យមានការចូលរួមឱ្យបានកាន់តែទូលំទូលាយ នៅឯសិក្ខាសាលាស្ដីពីជនរងគ្រោះ និងការចូលរួមជាមួយក្រុមសិក្ខាសាលា ដែលទទួលខុសត្រូវក្នុងការរៀបចំព្រឹត្តិការណ៍នេះ និងផ្ដល់យោបល់ជូនការិយាល័យរដ្ឋបាលអំពីគំនិតផ្ដួចផ្ដើមសមស្រប ដែលជាលទ្ធផលនៃការពិភាក្សានេះ។

យើងខ្ញុំត្រៀមខ្លួនក្នុងការរៀបចំនូវអ្វីដែលយើងខ្ញុំរំពឹងថា នឹងក្លាយជាកិច្ចពិភាក្សាប្រកបដោយផ្លែផ្កា ដែលអាចបង្កើតបានជាគំនិតផ្ដួចផ្ដើមដែលអាចអនុវត្តបាន។ ដូចដែលសហចៅក្រមរបាយការណ៍បានថ្លែងថា៖ ដំណាក់កាលថ្មីដ៏គួរឱ្យចាប់អារម្មណ៍នៅក្នុងប្រវត្តិសាស្ត្រនៃ អ.វ.ត.ក បានចាប់ផ្ដើមបើកចំហចាប់ពីពេលនេះតទៅ។

# សារលិខិតរបស់សហចៅក្រម
# របាយការណ៍

**ដោយសារយើងមាន**
**ជំនឿចិត្តយ៉ាងមុតមាំថា**
**ពេលវេលាបានមកដល់**

យើងសូមស្វាគមន៍ការបោះពុម្ពផ្សាយរបាយការណ៍របស់យើង។

យើងបានទទួលយកការងារនេះ ដោយសារយើងមានជំនឿចិត្តយ៉ាងមុតមាំថា ពេលវេលាបានមកដល់ហើយ ដែលដំណាក់កាលនៅសេសសល់របស់តុលាការនេះ និងតុលាការអន្តរជាតិនាពេលអនាគតនេះគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ។

នៅពេលយើងរៀបចំរបាយការណ៍នេះ យើងបានទទួលការលើកទឹកចិត្តដោយមតិត្រឡប់វិជ្ជមាននានា។ របាយការណ៍នេះផ្អែកទៅលើមតិយោបល់នានា នៅក្នុងសំណើជាច្រើនដែលបានដាក់មកយើង។ ចាប់តាំងពីរយៈពេលកំណត់ក្នុងការដាក់សំណើនានាបានកន្លងផុត មានដៃគូពាក់ព័ន្ធផ្សេងទៀតបានទាក់ទងមកយើង ដោយបង្ហាញពីគោលបំណងចង់ចូលរួមនៅក្នុងដំណើរការនេះ។ យើងបានប្រាប់ពួកគេនូវអ្វីដែលយើងសូមបញ្ជាក់ពេលនេះត្រង់នេះឡើងវិញថា៖ របាយការណ៍នេះគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ។

យើងបានដឹងថា ការិយាល័យរដ្ឋបាលកំពុងបង្កើនសន្ទុះដោយតាក់តែងដំណើរការការងាររបស់ខ្លួនហើយ។ ឆ្នាំ២០២២ ជាពេលវេលាអន្តរកាល។ បើតាមក្របខ័ណ្ឌគតិយុត្ត ដំណាក់កាលនៅសេសសល់អាចចាប់ផ្តើមដំណើរការបាន នៅពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការត្រូវបានបញ្ចប់។ មានការគ្រោងទុកថា នីតិវិធីតុលាការនឹងអាចបញ្ចប់នៅដំណាច់ឆ្នាំ២០២២។

**របាយការណ៍នេះគ្រាន់តែជា**
**ការចាប់ផ្តើមប៉ុណ្ណោះ**

យើងមានសេចក្តីរីករាយដែលបានទទួលព័ត៌មានថា សិក្ខាសាលាមួយនឹងគ្រោងរៀបចំនៅខែឧសភា ដែលជាដំណើរការដំបូងដ៏សំខាន់មួយក្នុងការនាំយកដៃគូពាក់ព័ន្ធជាច្រើនមកប្រជុំរួមគ្នា។

យើងយល់ថា វិធីសាស្ត្រនាពេលនោះ ក៏ដូចជាសម្រាប់ដំណើរការទាំងមូលដែរ នឹងជំរុញឱ្យមានការចូលរួមបែបបរិយាប័ន្ន និងធានានូវភាពជាម្ចាស់របស់ប្រជាជនកម្ពុជា។ យើងយល់ឃើញថា ចំណុចទាំងនេះគឺ បុរេលក្ខខណ្ឌ ដើម្បីសម្រេចឱ្យបាននូវគោលបំណងធំនៅក្នុងដំណើរការទាំងមូលគឺ៖ ចីរភាពនៃគំនិតផ្តួចផ្តើម ដែលចាប់ផ្តើម នៅក្នុងដំណាក់កាលនៅសេសសល់។

នៅឯសិក្ខាសាលានោះនឹងមានការលើកឡើងនូវគំនិត និងគម្រោងនានាជាច្រើន។ ដោយហេតុថា ឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងយេនឌ័រ (ឧទាហរណ៍ អាពាហ៍ពិពាហ៍ដោយបង្ខំការរំលោភផ្លូវភេទ) ជាបញ្ហាគន្លឹះ

## ការបង្កើតគំនិតផ្តួចផ្តើមពាក់ព័ន្ធជនរងគ្រោះថាជាមូលដ្ឋានគ្រឹះមួយដែលបានទទួលស្គាល់សម្រាប់ដំណាក់កាលនៅសេសសល់នៃតុលាការអន្តរជាតិនាពេលអនាគត នឹងផ្តល់នូវលទ្ធផលគួរជាទីពេញចិត្តសម្រាប់សម្រាប់រយៈពេលយូរអង្វែង។

នៅពេលសវនាការ និងដោយពិចារណាទៅលើបរិបទរបស់កម្ពុជា និងបរិបទអន្តរជាតិ នៅពេលពិភាក្សាពីបញ្ហាយេនឌ័រ យើងជឿថា គម្រោងយេនឌ័រស្តីអំពីសិទ្ធិអំណាច/ដែលមានលក្ខណៈរសើប នឹង ស្របជាមួយទស្សនៈនេះយ៉ាងល្អ។

ទោះបីភាពជាម្ចាស់របស់ប្រជាជនកម្ពុជានឹងក្លាយជាចំណុចគន្លឹះសម្រាប់ការអនុវត្តក្តី ក៏គំនិតផ្តួចផ្តើមនេះនឹងមានអត្ថន័យទូលំទូលាយជាងនេះ។ ប្រសិនបើដំណើរការនេះបានជោគជ័យ វាអាចក្លាយជាគំរូសម្រាប់តុលាការអន្តរជាតិនាពេលអនាគត។ ការបង្កើតគំនិតផ្តួចផ្តើមពាក់ព័ន្ធជនរងគ្រោះថាជាមូលដ្ឋានគ្រឹះមួយនិងបានទទួលស្គាល់សម្រាប់ដំណាក់កាលនៅសេសសល់នៃតុលាការអន្តរជាតិនាពេលអនាគត នឹងផ្តល់នូវលទ្ធផលគួរជាទីពេញចិត្តសម្រាប់ពេលយូរអង្វែង។

ការរំពឹងទុកនេះទំនងជាធ្វើឱ្យការចូលរួមក្នុងដំណើរការនេះកាន់តែមានក្តីរំភើបថែមទៀត។

**យើងសូមជូនពរឱ្យសិក្ខា សា លានេះ និងគំនិតផ្តួចផ្តើមជារួមដំណើរការទៅមុខដោយជោគជ័យ។**

ចៅក្រម យូរ ឧត្តរា និង
ចៅក្រម Claudia FENZ

# ប្រវត្តិរូបសហចៅក្រមរបាយការណ៍



## ចៅក្រម យូរ ឧត្ដរា

លោកចៅក្រម យូរ ឧត្ដរា (កម្ពុជា) បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតច្បាប់នៅសាកលវិទ្យាល័យជាតិកាហ្សាក់ស្ថាន(Kazakhstan)។ លោកបានបម្រើការងារជាមន្ត្រីរាជការនៅនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងរដ្ឋប្បវេណីពីឆ្នាំ ១៩៩៥-១៩៩៦ ជាប្រធានការិយាល័យសហប្រតិបត្តិការអាស៊ាន និងអន្តរជាតិពីឆ្នាំ១៩៩៦-២០០១ ជាចៅក្រម និងជាប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិឆ្នាំ២០០១-២០០២។ ចាប់តាំងពីឆ្នាំ២០០២ មក លោកបានបម្រើការងារជាចៅក្រមនៅតុលាការកំពូល លោកបានស្រាវជ្រាវផ្នែកច្បាប់ជាតិ និងអន្តរជាតិ និងបានចូលរួមក្នុងនាមជាសិក្ខាកាម និងជាគ្រូឧទ្ទេសនាមក្នុងវគ្គបណ្ដុះបណ្ដាលជាច្រើនអំពីច្បាប់។ លោកក៏ជាគ្រូបណ្ដុះបណ្ដាលច្បាប់នៅសាលាភូមិន្ទចៅក្រមផងដែរ។

លោកចៅក្រម យូរ ឧត្ដរា បានទទួលការតែងតាំងជាចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក។



## លោកស្រីចៅក្រម
## ក្លោឌៀ ហ្វិន
## Claudia FENZ

លោកស្រី ចៅក្រម ក្លោឌៀ ហ្វិន ទទួលបានសញ្ញាប័ត្រ បណ្ឌិតច្បាប់ ពីសាកលវិទ្យាល័យក្រុងវីយែន។ នៅឆ្នាំ១៩៨៤ លោកស្រីបានទទួលការតែងតាំងជាចៅក្រមក្នុងប្រព័ន្ធតុលាការយុត្តិធម៌អន្តរជាតិព្រហ្មទW◌ូWទ្រីសដែលបើកផ្លូវឱ្យលោកស្រីទទួលបានតំណែងក្នុងវិស័យតុលាការអស់រយៈពេលជាង២០ឆ្នាំ ខាងផ្នែកស៊ើបអង្កេត ជំនុំជម្រះក្តី និងឧទ្ធរណ៍។ នៅឆ្នាំ២០០៤ លោកស្រីត្រូវបានតែងតាំងជាចៅក្រមអន្តរជាតិសម្រាប់បេសកកម្មរដ្ឋបាលបណ្តោះអាសន្ននៅកូសូវ៉ូ ដោយធ្វើការងារពាក់ព័ន្ធនឹងការរៀបចំបទឧក្រិដ្ឋកម្មជាតិសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម។ ចន្លោះឆ្នាំ២០០៦-២០០៨ លោកស្រីចៅក្រម ក្លោឌៀ ហ្វិន ជាប្រធានអង្គភាពនីតិរដ្ឋនៅក្នុងបេសកកម្ម EUPOL COPPS ដែលជាស្ថាប័នមួយជួយដល់ផ្នែកយុត្តិធម៌ឧក្រិដ្ឋកម្ម ប្រទេសប៉ាឡេស្ទីន។

លោកស្រីចៅក្រម ក្លោឌៀ ហ្វិន បានទទួលការតែងតាំងជាចៅក្រមបម្រុងនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នៅក្នុងឆ្នាំ២០០៦ និងជាចៅក្រមពេញសិទ្ធិនៅក្នុងឆ្នាំ២០១៤។

# សាវតារនិងប្រវត្តិ

ដោយធ្វើការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មហាសន្និបាតអង្គការសហប្រជាជាតិបានស្នើសុំទៅអគ្គលេខាធិការ ដើម្បីកំណត់មុខងារដែលនៅសេសសល់របស់ អ.វ.ត.ក ក្រោយបញ្ចប់អាណត្តិការងាររបស់ខ្លួន និងបង្កើតព្រមទាំងរៀបចំកំណត់យកក្របខ័ណ្ឌការងារសមស្របមួយតាមជាក់ស្តែង[១]។

ក្របខ័ណ្ឌការងារដែលត្រូវបង្កើតឡើង ក្នុងទម្រង់នៃសេចក្តីព្រាងកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ទាក់ទងទៅនឹងការកាត់សេចក្តី នៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ[២] ត្រូវបានអគ្គលេខាធិការយល់ព្រមឱ្យយកទៅអនុម័ត ដែលបានធ្វើឡើងកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១។ អ្នកតំណាងរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបន្ថែមនេះ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ និងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១។

នៅត្រង់ផ្នែកពាក់ព័ន្ធនឹងជនរងគ្រោះ កិច្ចព្រមព្រៀងបន្ថែមទទួលស្គាល់ថា មុខងារដែលបានកាត់បន្ថយ តែមានសារៈសំខាន់ នឹងចាំបាច់ត្រូវតែអនុវត្ត ពាក់ព័ន្ធនឹងជនរងគ្រោះ នៅពេលដែល អ.វ.ត.ក បានបញ្ចប់រួចរាល់នូវកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ។ មាត្រា ២ តម្រូវឱ្យ អ.វ.ត.ក "បន្ត... ផ្តល់ការការពារជនរងគ្រោះ"ចែករំលែកព័ត៌មានជូនសាធារណជនពាក់ព័ន្ធអង្គជំនុំជម្រះ" និង "តាមដានការអនុវត្តសំណងដែលបានផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណី"។

អាស្រ័យហេតុនេះ ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលបានសម្រេចស្នើសុំយោបល់លើការអនុវត្តអាណត្តិការងារដែលបានស្នើឡើង ពីសំណាក់សហចៅក្រមរបាយការណ៍ពីររូប ក្នុងចំណោមចៅក្រមទាំងអស់នៅ អ.វ.ត.ក ដែលនឹងអនុវត្តមុខងារនេះ ទៅតាមតួនាទីរៀងខ្លួនរបស់ពួកគេ ដោយមិនពាក់ព័ន្ធជាមួយនឹងការតែងតាំងជាចៅក្រមរបស់ពួកគេឡើយ។ សហចៅក្រមរបាយការណ៍មានភារកិច្ច ផ្តល់ជាពិសេស "ការពន្យល់ និងអនុសាសន៍ អំពីការអនុវត្តដែលអាចធ្វើទៅបាន ដែលសមស្របនិងមានអត្ថន័យសម្រាប់ជនរងគ្រោះ ដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។ សហចៅក្រមរបាយការណ៍នោះគឺចៅក្រម យូ ឧត្តរា និងចៅក្រម Claudia FENZ។

[១] សូមមើល សេចក្តីសម្រេចរបស់មហាសន្និបាតលេខ A/RES/73/279, A/RES/74/263 និង A/RES/75/257។

[២] សេចក្តីសម្រេចរបស់មហាសន្និបាតលេខ A/75/809, ឧបសម្ព័ន្ធ។

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ ២០២១ សហចៅក្រមរបាយការណ៍ បានចេញជាសាធារណៈនូវ "សំណើសុំការចូលរួមមតិយោបល់ លើមុខងារដែលនៅសេសសល់ ទាក់ទងនឹងជនរងគ្រោះ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"៣។ សហចៅក្រមរបាយការណ៍ បានទំនាក់ទំនងទៅអ្នកពាក់ព័ន្ធនានារបស់ អ.វ.ត.ក ឱ្យដាក់ជូនជាលាយលក្ខណ៍អក្សរ នូវគំនិតសម្រាប់ការផ្ដួចផ្ដើមនានា ពាក់ព័ន្ធជនរងគ្រោះ ដែល អ.វ.ត.ក អាចអនុវត្តបាន។

៣ សំណើសុំការចូលរួមមតិយោបល់ លើមុខងារដែលនៅសេសសល់ ទាក់ទងនឹងជនរងគ្រោះ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ២០២១។ សូមមើល https://www.eccc.gov.kh/en/articles/call-contribution-ideas-extraordinary-chambers-courts-cambodia-eccc-residual-functions។

សហចៅក្រមរបាយការណ៍តម្រូវថា ការចូលរួមចំណែកនោះត្រូវមានទម្រង់ដែលទូលាយ ប៉ុន្តែមិនលើសពី ២ទំព័រ ជាភាសាអង់គ្លេស និង/ឬ ៣ទំព័រ ជាភាសាខ្មែរ ដោយធ្វើការពន្យល់អំពីថាតើគំនិតផ្ដួចផ្ដើមដែលស្នើឡើងនោះ គឺជាជំនួយប្រកបដោយអត្ថន័យ និង ឋិតថេរដោយរបៀបណា សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះនៃរបបខ្មែរក្រហម និងសាធារណជនទូទៅ។ អ្នកចូលរួមគំនិត ត្រូវបានស្នើឱ្យសង្ខេបលក្ខណៈពិសេសជាគន្លឹះ នៃសំណើសុំ ដែលក្នុងនោះរួមមាន សំអាងហេតុ ក្រុមគោលដៅ និងចិរភាពសមស្រប។ សហចៅក្រមរបាយការណ៍បានចង្អុលបញ្ជាក់ថា ពាក្យ "គំនិតផ្ដួចផ្ដើម" គឺមិនមែនមានន័យកម្រិតត្រឹមទម្រង់ និងខ្លឹមសារ នៃសំណើណាមួយឡើយ។ ពាក្យ "ជនរងគ្រោះ"ត្រូវបកស្រាយប្រហែលគ្នាក្នុងន័យទូលាយ និងមិនកម្រិតត្រឹមអ្នកទាំងឡាយណា ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីផ្លូវច្បាប់ នៅចំពោះមុខ អ.វ.ត.ក ឡើយ។

**មាត្រា ២ "កិច្ចព្រមព្រៀងបន្ថែមទៅលើ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា" តម្រូវឱ្យអ.វ.ត.ក "បន្ត...ផ្ដល់ការការពារជនរងគ្រោះ," "ចែករំលែកព័ត៌មានជូនសាធារណជនពាក់ព័ន្ធអង្គជំនុំជម្រះ" និង "តាមដានការអនុវត្តសំណងដែលបានផ្ដល់ជូនដើមបណ្ដឹងរដ្ឋប្បវេណី"។**

សហចៅក្រមរបាយការណ៍ កត់សម្គាល់ថា អ្នកចូលរួមគួរកត់ចំណាំនូវកត្តាមួយចំនួនដែលរួមមាន តែមិនកម្រិតត្រឹមៈ វិសាលភាពនៃហេតុការណ៍ និងលក្ខណៈនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើង ហើយដែលជះឥទ្ធិពលទៅលើប្រជាជនភាគច្រើន នៅអំឡុងពេលនោះ ហើយដែលផលវិបាកនៅបន្តមាន រហូតមកទល់បច្ចុប្បន្ន។ ការពិតដែលថា ប្រជាជនកម្ពុជានាពេលបច្ចុប្បន្នជាងពាក់កណ្ដាល មិនទាន់ចាប់កំណើតនៅឡើយ នៅពេលដែលមានហេតុការណ៍នោះ។ អត្ថិភាពនៃគម្រោងដែលអាចបំពេញបន្ថែមទៀត រួមទាំងគម្រោងដែលបានអនុវត្តរួចហើយ ដូចជាការផ្ដល់សំណង និងវិធានការណ៍មិនមែនតាមផ្លូវតុលាការ។ រយៈពេលផ្ដើមដំបូង សម្រាប់មុខងារដែលនៅសេសសល់ ត្រូវបានប្រមើលឃើញថាមានរយៈពេល ៣ ឆ្នាំ ហើយថា លទ្ធភាពក្រុមគោលដៅសម្រាប់គំនិតផ្ដួចផ្ដើម អាចរួមមាន ប៉ុន្តែមិនកម្រិតត្រឹម ជនរងគ្រោះដោយផ្ទាល់ និងកូនចៅរបស់ពួកគេ លោកគ្រូអ្នកគ្រូ សិស្សនិស្សិតខ្មែរ និងបរទេស និងអ្នកសិក្សាលើគ្រប់មុខជំនាញ សាធារណជន និងប្រព័ន្ធផ្សព្វផ្សាយ។



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមទិវាចងចាំថ្ងៃទី២០ ខែឧសភា នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

សហចៅក្រមរបាយការណ៍ ទទួលបានសារណាចំនួន ២០ ពីអ្នកពាក់ព័ន្ធនានានា។ សហចៅក្រមរបាយការណ៍បានជំរុញនិងធ្វើការយ៉ាងសកម្ម ជាមួយអ្នកពាក់ព័ន្ធនានា ដែលបានទំនាក់ទំនងមកពួកគាត់។

# សកម្មភាពពាក់ព័ន្ធនឹងជនរងគ្រោះ នៅតុលាការព្រហ្មទណ្ឌនានាដែលមានចរិកលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម នៅដំណាក់កាលដែលនៅសេសសល់

យើងបានពិនិត្យការអនុវត្ត និងក្របខ័ណ្ឌគតិយុត្តិ ពាក់ព័ន្ធដំណាក់កាលដែលនៅសេសសល់ ទាក់ទងជនរងគ្រោះ នៃតុលាការអន្តរជាតិដទៃទៀត ដើម្បីធ្វើជាគោលការណ៍ណែនាំ។

តុលាការទាំងនោះរួមមាន អង្គជំនុំជម្រះពិសេសអាហ្វ្រិក តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ៉ាន់ដា (តុលាការ ICTR) តុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី (តុលាការ ICTY) ក្រុមប្រឹក្សាជំនុំជម្រះច្បាប់លេខ ៦៤ នៃតុលាការប្រទេសកូសូវ៉ូ អង្គជំនុំជម្រះអ្នកជំនាញ និងការិយាល័យរដ្ឋអាជ្ញាអ្នកជំនាញ ប្រទេសកូសូវ៉ូ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (តុលាការ SCSL) ក្រុមប្រឹក្សាជំនុំជម្រះពិសេស និងអង្គភាពឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត និងតុលាការពិសេសសម្រាប់ប្រទេសលីបង់។

ទោះបីជាតុលាការទាំងអស់នោះភាគច្រើន បានបង្កើតក្របខ័ណ្ឌគតិយុត្តិ សម្រាប់ដំណាក់កាលដែលនៅសេសសល់ រួមមានបទប្បញ្ញត្តិដែលធានា ការការពារជនរងគ្រោះនិងសាក្សីក្តី តែហាក់ដូចជាមានតែតុលាការ **SCSL ប៉ុណ្ណោះ ដែលដំណើរការបន្ថែមទៀត សម្រាប់ការចូលរួមជាមួយជនរងគ្រោះ និងសាធារណជន ក្នុងលក្ខណៈដែលមានភាពស៊ីជម្រៅ។** យន្តការដែលនៅសេសសល់ជាអន្តរជាតិ សម្រាប់តុលាការព្រហ្មទណ្ឌ (IRMCT) មិនបានប្រមើលមើលបន្ថែមលើជនរងគ្រោះឡើយ ពាក់ព័ន្ធសកម្មភាពដែលនៅសេសសល់។ តុលាការ SCSL ត្រូវបានបង្កើតឡើងតាមច្បាប់ជាតិ ដូចគ្នានឹង អ.វ.ត.ក។ តុលាការទាំងពីរគឺជាតុលាការចម្រុះ (Hybrid Court) សម្រាប់សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ និងច្បាប់ជាធរមាននានា។ តុលាការទាំងពីរមានទីតាំងស្ថិតនៅក្នុងតំបន់នៃជម្លោះដែលចោទប្រកាន់។ តុលាការ SCSL បានប្រែក្លាយទៅជាតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន សម្រាប់ដំណាក់កាលដែលនៅសេសសល់ នៅក្នុងឆ្នាំ២០១៣។

ចន្លោះពីឆ្នាំ ២០១៣ ដល់ឆ្នាំ២០២០ មុខងារដែលនៅសេសសល់ដូចខាងក្រោម ត្រូវបានអនុវត្តនៅតុលាការ SCSL៖ ការរក្សា ការអភិរក្សនិងការគ្រប់គ្រងបណ្ណសារ, ការការពារនិងគាំពារសាក្សី ការផ្តល់ជំនួយ

ដល់ស្ថាប័នរដ្ឋអាជ្ញាជាតិការតាមដានការផ្តន្ទាទោសដាក់ពន្ធនាគារ/ការលើកលែងទោស/ការសម្រាលទោស/ការដោះលែងមុនកាលកំណត់លើ Johnny Paul Koroma ការត្រួតពិនិត្យឡើងវិញលើ ការផ្តន្ទាទោស និងការលើកលែងការចោទប្រកាន់ ការប្រមាថកិច្ចដំណើរការនីតិវិធីតុលាការ បញ្ហាជំនួយផ្លូវច្បាប់ និងមេធាវីការពារក្តី បណ្តឹងទាមទារសំណង និង ការរារាំងការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ។

ដំណើរការដែលតុលាការនោះបានជ្រើសរើសដើម្បីរៀបចំដំណាក់កាលដែលនៅសេសសល់ គឺមានលក្ខណៈជាការណែនាំ។

ដោយគ្រោងទុកនូវការបិទបញ្ចប់តុលាការ SCSL សហភាពអឺរ៉ុបបានផ្តល់មូលនិធិសម្រាប់ ការស្ទង់មតិបែបវាយតម្លៃដោយឯករាជ្យទៅលើការងាររបស់តុលាការ SCSL ហើយតុលាការ SCSL បានរៀបចំការផ្សព្វផ្សាយជូនទៅដល់អ្នកដែលបានចូលរួមជាមួយតុលាការ និងធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនងរបស់ពួកគេ។

យើងបានដកស្រង់ការពណ៌នាអំពីគម្រោង និង/ឬការចេញផ្សាយជាសាធារណៈ ពីតុលាការ SCSL និងតុលាការ RSCSL[៤] ដែលត្រូវបានចាត់ទុកថាជាការងារនៅសេសសល់ ដោយសារតែចំណុចទាំងអស់នេះ អាចផ្តល់ជាការជំរុញសម្រាប់សំណើសុំគម្រោងទៅមុខទៀតរបស់ អ.វ.ត.ក សម្រាប់ដំណាក់កាលនៅសេសសល់របស់ អ.វ.ត.ក និងជាការណែនាំនៅពេលដែលពាក់ព័ន្ធលើផ្នែក៖

- តុលាការពិសេសមានភាពងាយស្រួល, ច្បាប់មនុស្សធម៌អន្តរជាតិមានភាពងាយស្រួល សន្ធានុក្រមច្បាប់ អនុសាសន៍អំពីឧត្តមានុវត្ត សម្រាប់ការការពារនិងគាំទ្រសាក្សី។

- តុលាការពិសេសសម្រាប់ដំណាក់កាលដែលនៅសេសសល់មានភាពងាយស្រួល គោលនយោបាយចូលពិនិត្យមើលកំណត់ត្រារបស់តុលាការ RSCSL)។

- **"មានការទទួលខុសត្រូវខ្ពស់បំផុត"** យុត្តិសាស្ត្រដែលបានជ្រើសរើសរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ត្រូវបានចេញផ្សាយដោយចៅក្រមនៃតុលាការ RSCSL កាលពីថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩ និងប្រមូលចងក្រងនូវយុត្តិសាស្ត្រពិសេស របស់តុលាការ SCSL ជាកម្រងតែមួយ។

- **សារមន្ទីរសន្តិភាពសៀរ៉ា ឡេអូន** ដែលស្ថិតលើអតីតអគារសន្តិសុខ ដែលបានកែសម្រួលរួច របស់តុលាការពិសេស គឺជាការងាររួមគ្នារបស់តុលាការនិងរដ្ឋាភិបាលប្រទេសសៀរ៉ាឡេអូន។ ជាគ្រឹះស្ថានជាតិឯករាជ្យមួយ សារមន្ទីរសន្តិភាពគឺជាការ

[៤] http://www.rscsl.org។



អភិបាលខេត្តកោះកុងស្តាប់ការពន្យល់រៀបរាប់ អំពីការរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម



អ្នករស់រានមានជីវិតពីមន្ទីរសន្តិសុខ ស-២១ ជុំ ម៉ី (ទី២ ខាងឆ្វេង) ប៊ូ ម៉េង (កណ្តាល) និង នង ចាន់ផល (ទី១ ខាងស្តាំ) ជាមួយនឹង ឯកឧត្តម បណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី (ទី២ ខាងស្តាំ) និង ឯកឧត្តម Joachim Baron von MARSCHELL អតីតឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា (ទី១ ខាងឆ្វេង)

ផ្តល់កិត្តិយសដល់ជនរងគ្រោះដោយសង្គ្រាម ការរក្សាអភិរក្សប្រវត្តិសាស្ត្រ សង្គ្រាមនិងរឿងរ៉ាវនៃដំណើរការសន្តិភាព ការកសាងសន្តិភាព និងការលើកកម្ពស់វប្បធម៌សិទ្ធិមនុស្ស។

- **កម្មវិធីការពារសាក្សីជាតិ** ដោយបង្កើតឡើងផ្អែកលើបទពិសោធន៍របស់ខ្លួន ក្នុងដំណើរការកម្មវិធី ការពារសាក្សី ដែលទទួលបានជោគជ័យត្រចះត្រចង់នោះ តុលាការពិសេសបានសហការជាមួយ អាជ្ញាធរជាតិរបស់សៀរ៉ាឡេអូន បង្កើតអង្គភាពការពារសាក្សីដែលនឹងជួយគាំទ្រ ដល់តុលាការជាតិរបស់ប្រទេសនេះ។អង្គភាពថ្មីនេះស្ថិតនៅក្នុងកងនគបាលរបស់សេរ៉ាឡេអូន ត្រូវបានប្រមើលមើលថាជា មធ្យោបាយមួយក្នុងការគាំទ្រដល់ការចោទប្រកាន់ បទល្មើសធ្ងន់ធ្ងរដូចជា ឧក្រិដ្ឋកម្មដែលមានជាបណ្តាញ ការរត់ពន្ធគ្រឿងញៀន ការរត់ពន្ធមនុស្ស អំពើពុករលួយ និងអំពើហឹង្សាលើយេនឌ័រ នៅក្នុងប្រព័ន្ធជាតិ។ អង្គភាពនេះក៏ជួយផងដែរដល់តុលាការ RSCSL ក្នុងការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់ដែលនៅបន្ត ដើម្បីធានាសុវត្ថិភាពរបស់សាក្សីដែលមកផ្តល់សក្ខីកម្មនៅក្នុង សវនាការ របស់តុលាការពិសេស។

- **កម្មវិធីអភិវឌ្ឍបណ្ណសារ** ទោះបីជាបណ្ណសារដើមត្រូវបានរក្សាទុកនៅទីក្រុងឡាអេក្តី តុលាការនេះបានបង្កើតបណ្ណសារ



ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមទស្សនាពិព័រណ៍ចល័ត ស្តីពីជនរងគ្រោះនៃរបបខ្មែរក្រហម នៅសៀមរាប

មួយនៅប្រទេសសៀរ៉ាឡេអូន ដែលរក្សាទុកនូវឯកសារចម្លងនៃកំណត់ត្រាសាធារណៈរបស់តុលាការពិសេស។ ការរក្សាទុកទាំងនេះ នឹងរួមបញ្ចូលជាមួយកំណត់ត្រា របស់គណៈកម្មការផ្សះផ្សានិងស្វែងរកការពិត និងគណៈកម្មការជាតិសម្រាប់ការរំសាយសព្វាវុធ ការរំសាយកងទ័ព និងការធ្វើសមាហរណកម្មឡើងវិញ ដើម្បីបង្កើតជាមជ្ឈមណ្ឌលស្រាវជ្រាវរួមមួយសម្រាប់យុត្តិធម៌អន្តរកាល បន្ទាប់ពីមានសង្គ្រាមស៊ីវិលនៅសៀរ៉ាឡេអូន។ បច្ចុប្បន្ននេះ ប្រទេសសៀរ៉ាឡេអូនមិនមានស្ថាប័ន ដែលមានសម្ភារៈឬប្រព័ន្ធដែលអាចរក្សាទុកដោយត្រឹមត្រូវនូវបណ្ណសារជាអចិន្ត្រៃយ៍។ សារមន្ទីរសន្តិភាព បានផ្តល់ដំណោះស្រាយបណ្តោះអាសន្ន ដែលអាចទទួលអ្នកប្រើប្រាស់ក្នុងចំនួនតិច ប៉ុន្តែទីតាំងដែលប្រើសម្រាប់តែបណ្ណសារ នឹងធ្វើឱ្យកាន់តែប្រសើរឡើងដល់ការចូលមើល និងការគ្រប់គ្រង ព្រមទាំងការអភិរក្សកំណត់ត្រា។ តុលាការ SCSL រៀបចំកម្មវិធីបណ្តុះបណ្តាលលើបណ្ណសារមួយចំនួន សម្រាប់បុគ្គលិកបណ្ណសារជាតិ និងស្ថាប័នដទៃទៀត ក្នុងការគ្រប់គ្រងបណ្ណសារ។ មានតម្រូវការធនធានបន្ថែម សម្រាប់ការបង្កើតទីតាំងដែលកសាងឡើងក្នុងគោលបំណងជាក់ស្តែង ដែលនឹងអភិរក្សដល់ឯកសារសាធារណៈ របស់បណ្ណសារតុលាការពិសេស សម្រាប់មនុស្សជំនាន់ក្រោយ។

- **លើកកម្ពស់បទដ្ឋានការឃុំឃាំង និងសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ស្ត្រីនិងកុមារ** នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ មន្ទីរឃុំឃាំងរបស់តុលាការពិសេស ត្រូវបានផ្ទេរទៅឱ្យសេវាពន្ធនាគារសៀរ៉ាឡេអូន ដោយមានគោលដៅប្រើប្រាស់ទីតាំងនេះ ធ្វើជាពន្ធនាគារសម្រាប់អ្នកជាប់ឃុំជាស្ត្រីនិងកុមារ។ នាពេលបច្ចុប្បន្ននេះ មានទីកន្លែងតិចតួចនៅក្នុងប្រព័ន្ធពន្ធនាគារដែលអាចដោះស្រាយបានចំពោះតម្រូវការពិសេសរបស់ស្ត្រីនិងកុមារ។ គម្រោងនេះមានគោលដៅ ប្រើប្រាស់ជំនាញនៅតុលាការពិសេស ដើម្បីជួយដល់សេវាពន្ធនាគារ ក្នុងការកែលម្អពន្ធនាគារ និងបណ្តុះបណ្តាលបុគ្គលិកពន្ធនាគារ ឱ្យលើកកម្ពស់គុណភាពនៃការយកចិត្តទុកដាក់ ដែលត្រូវផ្តល់សម្រាប់ទីតាំងថ្មី។ ការ បណ្តុះបណ្តាលត្រូវបានធ្វើឡើងសម្រាប់ មន្ត្រីពន្ធនាគារនៅទូទាំងប្រទេស ហើយនឹងផ្តោតទៅលើបទដ្ឋានអន្តរជាតិសម្រាប់ការឃុំឃាំងស្ត្រីនិងកុមារ។ ជាតុផ្សំទីពីរនៃគម្រោង នឹងបណ្តុះបណ្តាលមេធាវីដែលផ្តល់សេវាដោយស្ម័គ្រចិត្ត ចំពោះស្ត្រីនិងកុមារ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពួកគេ អំពីតម្រូវការរបស់ក្រុមជនងាយរងគ្រោះ និងពង្រឹងដល់ជំនាញតស៊ូមតិរបស់ពួកគេ។ មានតម្រូវការមូលនិធិសម្រាប់ឧបករណ៍ និងការកែលម្អដែលលចាំបាច់នៅតាមទីតាំងឃុំឃាំង និងបណ្តុះ

បណ្តាលបុគ្គលិកផ្តល់សេវានៅពន្ធនាគារ និងមេធាវី លើផ្នែកពាក់ព័ន្ធនឹងយុត្តិធម៌យេនឌ័រ និងកុមារ។

- **ការកសាងសមត្ថភាព៖ កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ** តុលាការពិសេសបានជ្រើសរើស អ្នកជំនាញនាំមុខនៅក្នុងវិស័យយុត្តិធម៌នានានៅលើពិភពលោក។ មានការរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីផ្ទេរជំនាញទាំងអស់នេះ ទៅប្រព័ន្ធយុត្តិធម៌ជាតិ។ ប្រធានបទនៃការបណ្តុះបណ្តាល រួមមាន ការគ្រប់គ្រងកំណត់ត្រា ការបកប្រែ ការគ្រប់គ្រងរដ្ឋបាលរឿងក្តីកុមារ និងការបណ្តុះបណ្តាលការគ្រប់គ្រងនិងការកម្រិតសម្រាប់ឆ្នាំគុក និងអ្នកដទៃទៀត។ សហភាពអឺរ៉ុបបានផ្តល់ថវិកា ៥៥.០០០ ដុល្លារអាមេរិក សម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីកំណត់ត្រានិងការគ្រប់គ្រងព័ត៌មាន សម្រាប់បុគ្គលិកគ្រឹះស្ថានបណ្ណសារជាតិ និងផ្នែកបកប្រែរបស់តុលាការ។ មានតម្រូវការមូលនិធិសម្រាប់វគ្គបណ្តុះបណ្តាល ដូចជា ការបណ្តុះបណ្តាលមន្ត្រីតុលាការ (Magistrate) ការបណ្តុះបណ្តាលនគបាលសៀរ៉ាឡេអូន និងការបញ្ចូលច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ទៅជាច្បាប់ជាតិ ដូចជាឧក្រិដ្ឋកម្មលើយេនឌ័រជាដើម។



សហចៅក្រមរបាយការណ៍ លោកចៅក្រម យូរ ឧត្តរា និងលោកស្រីចៅក្រម Claudia FENZ ធ្វើបទបង្ហាញរបាយការណ៍ប្រឹក្សាយោបល់របស់ខ្លួន ស្តីពីសកម្មភាពពាក់ព័ន្ធជនរងគ្រោះ ជូនដល់ប្រធានរដ្ឋបាលស្តីទី និងអនុប្រធានរដ្ឋបាល

- **ក្លឹបគណនេយ្យភាពនាពេលនេះ (Accountability Now Clubs)** ដោយចាប់ផ្តើមនៅក្នុងឆ្នាំ២០០៣ តុលាការពិសេសតាមរយៈការផ្សព្វផ្សាយ បានចូលរួមជាមួយនិស្សិតសាកលវិទ្យាល័យ នៅតាមស្ថាប័នឧត្តមសិក្សានានា នៅទូទាំងប្រទេសសៀរ៉ាឡេអូន ហើយក្រោយមកនៅប្រទេសលីប៊ី បានគាំទ្រដល់និស្សិតក្នុងការបង្កើត ក្លឹបគណនេយ្យភាពនាពេលនេះ។ ក្លឹបនេះសម្រាប់និស្សិតសាកលវិទ្យាល័យ ចូលរួមក្នុងបញ្ហាយុត្តិធម៌ និងការទទួលខុសត្រូវ។ ក្នុងគោលដៅរយៈពេលខ្លី ក្លឹបនេះគាំទ្រដល់ការងាររបស់ផ្នែកផ្សព្វផ្សាយ នៅតាមទីតាំងសាកលវិទ្យាល័យ និងសហគមន៍នៅជុំវិញ ប៉ុន្តែក្លឹបគណនេយ្យភាពនាពេលនេះ ក៏នឹងធ្វើជាតុលាការពិសេសជាអចិន្ត្រៃយ៍ និងជានិរន្តន៍ផងដែរ។ ផ្នែកផ្សព្វផ្សាយផ្តល់ការបណ្តុះបណ្តាលដល់សមាជិក លើប្រធានបទសិទ្ធិមនុស្ស តុលាការពិសេស ការសរសេរនិងអនុវត្តគម្រោង ការជៀសវាងការគ្រប់គ្រងមិនត្រឹមត្រូវនៅក្នុងអង្គភាព ការទំនាក់ទំនងជាមួយក្រុម និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ដោយសារតែតុលាការពិសេសជិតបិទបញ្ចប់អាណត្តិការងារខ្លួន ផ្នែកផ្សព្វផ្សាយធ្វើការជាមួយបណ្តាផ្នែកនៃក្លឹប ដើម្បីបង្កើតទៅជាស្ថាប័ន និងជួយដល់ពួកគេក្នុងការអនុវត្ត បទពិសោធន៍របស់ពួកគេ នៅក្នុងស្ថាប័ននានាក្នុងប្រព័ន្ធជាតិ។ នៅក្នុងឆ្នាំ ២០១០ សមាជិកក្លឹបគណនេយ្យភាពនាពេលនេះ ដែលបញ្ចប់ការសិក្សាពីតាមសាកលវិទ្យាល័យ

នានា បានបង្កើតសម្ព័ន្ធមួយ ដែលនាពេលនេះសម្ព័ន្ធនេះបានដំណើរការ ជាអង្គការឯករាជ្យ ដែលធ្វើការលើបញ្ហាទាក់ទងសិទ្ធិមនុស្ស និងនីតិរដ្ឋ។

- **វិទ្យាស្ថា នព័ត៌មានច្បាប់សៀរ៉ា ឡេអូន (គម្រោងកេរដំណែល OTP)** ត្រូវបានគេស្គាល់ច្បាស់ថាជា Sierra Lii វិទ្យាស្ថានព័ត៌មានច្បាប់សៀរ៉ាឡេអូនបានចាប់ផ្តើមនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៩ ដើម្បីផ្តល់ដោយឥតគិតថ្លៃតាមអនឡាញ នូវឯកសារនិងព័ត៌មានពាក់ព័ន្ធច្បាប់ចម្បងរបស់សៀរ៉ាឡេអូន។ ការិយាល័យរដ្ឋអាជ្ញាបានប្រមូលផ្តុំអ្នកពាក់ព័ន្ធចម្បងៗ ដូចជា សភា តុលាការមហាអយ្យការ គណៈមេធាវីសៀរ៉ាឡេអូន, មហាវិទ្យាល័យ Fourah Bay គណៈកម្មការកំណែទម្រង់ច្បាប់ និងសង្គមស៊ីវិល ដើម្បីបង្កើតជាអង្គភាពមួយ ដែលគ្រប់គ្រង Sierra Lii រយៈពេលវែង និងបង្កើតជាផែនការគ្រប់គ្រង ប្រកបដោយនិរន្តរភាពរយៈពេលវែង។

អ្នករស់រានមានជីវិតពីមន្ទីរសន្តិសុខ ស-២១ ជុំ ម៉ី (កណ្តាល) ប៊ូ ម៉េង (ខាងស្តាំ) និង ដើមបណ្តឹងរដ្ឋប្បវេណី ជិន ម៉េត (ខាងឆ្វេង) ទទួលសាលក្រមរបស់អង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០១ ប្រឆាំង កាំង ហ្គេក អ៊ាវ ហៅ ឌុច



- **ការបណ្តុះបណ្តាលនគបាលយុត្តិធម៌ (Police Prosecutor) (គម្រោងកេរដំណែល OTP)** នៅក្នុងឆ្នាំ២០០៩ និង២០១៣ ការិយាល័យរដ្ឋអាជ្ញា បានបណ្តុះបណ្តាលនគបាលយុត្តិធម៌ នៅក្នុងខេត្តទាំងបីរបស់ សៀរ៉ាឡេអូន នៅក្នុងតំបន់ភាគខាងលិច ដែលរួមបញ្ចូលទាំងរដ្ឋធានី Freetown។ ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ នៅតុលាការជាន់ទាបរបស់សៀរ៉ាឡេអូន ជាទូទៅធ្វើឡើងដោយនគបាលយុត្តិធម៌ មិនមែនអ្នកច្បាប់ឡើយ ដូច្នេះ ការបណ្តុះបណ្តាលត្រូវបានរៀបចំ ដើម្បីឱ្យសិក្ខាកាមយល់ដឹងអំពីមូលដ្ឋាននៃជំនាញចោទប្រកាន់ ការជំនុំជម្រះដោយសង្ខេប ការស៊ើបអង្កេតបឋម ការដំណើរការកិច្ចស៊ើបអង្កេតដោយត្រឹមត្រូវ យុទ្ធសាស្ត្រនិងក្រមសីលធម៌ ការគ្រប់គ្រងសាក្សីនិងជនរងគ្រោះ ការគ្រប់គ្រងរឿងក្តី ការសម្របសម្រួលរវាងនគបាល និងផ្នែករដ្ឋអាជ្ញា ការវិភាគវិធាននានា ពាក់ព័ន្ធនឹងព័ត៌មាន និងការបញ្ជូនរឿងទៅជំនុំជម្រះ និងជំនាញតស៊ូមតិជាមូលដ្ឋាន។ ការបណ្តុះបណ្តាលជាទូទៅកំណត់គោលដៅលើមន្ត្រីនគបាល ដែលមិនធ្លាប់ជានគបាលយុត្តិធម៌ ដោយសារតែនគបាលយុត្តិធម៌ចាស់ៗ ជាញឹកញាប់បានដឹងអំពីនីតិវិធីតាមរយៈបទពិសោធន៍រួចទៅហើយ។

- **គម្រោងឧត្តមានុវត្តន៍ របស់រដ្ឋអាជ្ញាអន្តរជាតិ (គម្រោងកេរតំណែល OTP)** ដោយសហការជាមួយការិយាល័យរដ្ឋអាជ្ញារបស់ តុលាការអន្តរជាតិ សម្រាប់អតីតប្រទេស យូហ្គោស្លាវី តុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ ការិយាល័យរដ្ឋអាជ្ញា បានរៀបចំចងក្រងឯកសារ អំពីការអនុវត្តដែលល្អពីការិយាល័យរដ្ឋអាជ្ញានីមួយៗ។ គម្រោង នេះប្រឹក្សាដោយទូលំទូលាយ ជាមួយសមាជិកនៃការិយាល័យរដ្ឋអាជ្ញានានា រួមទាំងអតីតរដ្ឋអាជ្ញានិងរដ្ឋអាជ្ញាបច្ចុប្បន្ន ហើយបានបង្កើតជាសៀវភៅណែនាំពី ឧត្តមានុវត្ត ដើម្បីជាជំនួយដល់អ្នកស៊ើបអង្កេត និងរដ្ឋអាជ្ញា នៅកម្រិតអន្តរជាតិ ព្រមទាំងស្ថាប័នរដ្ឋអាជ្ញាជាតិពាក់ព័ន្ធ។

# ការវិភាគទស្សនៈ

**អ.វ.ត.ក ឈានមុខគេក្នុងចំណោមតុលាការព្រហ្មទណ្ឌនានាដែលមានចរិតលក្ខណៈអន្តរជាតូបនីយកម្ម ចំពោះការចូលរួមរបស់ជនរងគ្រោះ។**

កិច្ចដំណើរការនីតិវិធីអន្តរជាតិ ជាញឹកញាប់គឺពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ ដែលរួមមានជនរងគ្រោះក្នុងចំនួនយ៉ាងច្រើន ដែលជាញឹកញាប់គឺច្រើនជាង ១០០០០០ នាក់។ ដោយសារហេតុផលផ្សេងៗគ្នា ភាគច្រើននៃជនរងគ្រោះនៃជម្លោះទ្រង់ទ្រាយធំ និងមានរយៈពេលយូរ មិនមកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីឡើយ។ ប៉ុន្តែពួកគាត់ និងកូនចៅគាត់ នៅរស់នៅក្នុងសង្គមដែលបែកបាក់ក្រោយជម្លោះ ហើយជាញឹកញាប់គឺរស់នៅក្បែរចារីកម្រិតទាប ដែលមិនត្រូវបាននាំយកមកធ្វើការជំនុំជម្រះឡើយ។ ជាញឹកញាប់ពួកគេត្រូវបង្ខំឱ្យដោះស្រាយចំពោះផលវិបាកជាបុគ្គល និងសង្គម ដែលបណ្តាលមកពីជម្លោះ ដោយមានការជួយគាំទ្រតិចតួច ឬក៏សឹងតែគ្មាន។

នៅក្នុងតុលាការព្រហ្មទណ្ឌ ជាច្រើន (ឬភាគច្រើន) ទាំងតុលាការព្រហ្មទណ្ឌជាតិ ទាំងតុលាការព្រហ្មទណ្ឌដែលមានចរិតលក្ខណៈអន្តរជាតូបនីយកម្ម ជនរងគ្រោះណាដែលចូលរួម ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺចូលរួមក្នុងនាមសាក្សី។ ដូច្នេះ តួនាទីរបស់ពួកគេ គឺកម្រិតត្រឹមផ្តល់ភស្តុតាង ពាក់ព័ន្ធឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ ការនេះបានផ្តល់ឱកាសតិចតួចណាស់ដែលពួកគេអាចពិភាក្សាលើសពីបញ្ហាក្នុងកម្រិតដ៏ចង្អៀតពាក់ព័ន្ធផ្ទាល់នឹងបទចោទដែលជនជាប់ចោទបានប្រព្រឹត្តលើពួកគេនិងអ្នកដទៃឲ្យរងការឈឺចាប់ធ្ងន់ធ្ងរ។ ការពិភាក្សាអំពីផលវិបាកនៃឧក្រិដ្ឋកម្ម ទៅលើពួកគេដោយផ្ទាល់ ទៅលើសាច់ញាតិ ឬកូនចៅរបស់ពួកគេ គឺកម្រនឹងអាចធ្វើទៅបានណាស់។

តួនាទីតាមកិច្ចដំណើរការនីតិវិធីរបស់ជនរងគ្រោះ គឺមានលក្ខណៈទូលំទូលាយជាង នៅពេលដែលពួកគេចូលរួម ក្នុងនាមជាភាគី (ដូចជាដើមបណ្តឹងរដ្ឋប្បវេណីជាដើម) ហើយពួកគេអាចផ្តល់សក្ខីកម្មបន្ថែម អំពីការឈឺចាប់និងការខូចខាត ដែលចារីបានបង្កឡើង។

បំណងប្រាថ្នាឱ្យមានជនរងគ្រោះច្រើនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ហើយរៀបរាប់អំពីរឿងរ៉ាវរបស់ពួកគេ ក្នុងលក្ខណៈជារួម និងមានភាពលម្អិតជាង គឺជារឿងអាចយល់បាន។ ប៉ុន្តែជាការមិនអាចបដិសេធបានដែលថា លក្ខណៈផ្លូវការនៃសាលសវនាការ ព្រមទាំងបណ្តាវិធាននីតិវិធីដ៏តឹងរឹង មិនអាចផ្តល់ទីកន្លែងប្រកបដោយសុវត្ថិភាព ដល់ជនរងគ្រោះ ដែលត្រូវការរៀបរាប់អំពីបទពិសោធន៍ដ៏ឈឺចាប់ឡើយ។

ការអនុវត្តបែបផ្លូវការដូច្នេះ គឺចំណាយពេលវេលាច្រើន។ ហេតុដូច្នេះតម្រូវការឱ្យមានជនរងគ្រោះច្រើននាក់ ជាញឹកញាប់គឺត្រូវថ្លឹងថ្លែងជាមួយសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះ ក្នុងពេលវេលាសមស្រប (សូមមើលមាត្រា ៦(១) គណៈកម្មាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស)។ នេះគឺជាហេតុផលដែលតុលាការខ្លះក្នុងចំណោមព្រហ្មទណ្ឌដែលមានចរិតលក្ខណៈអន្តរជាតូបនីយកម្ម ងាកចេញពីការផ្តល់ដល់ជនរងគ្រោះ នូវសិទ្ធិលើសពីសាក្សី ដែលការនេះបណ្តាលឱ្យជនរងគ្រោះ



ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមទស្សនាពិព័រណ៍ចល័ត ស្តីពីជនរងគ្រោះនៃរបបខ្មែរក្រហម នៅសៀមរាប

អាក់អន់ចិត្ត មិនមានការគាំទ្រ និងមានអារម្មណ៍ថា មិនបានទទួលនូវយុត្តិធម៌។

អ.វ.ត.ក ឈានមុខគេ ក្នុងចំណោមតុលាការព្រហ្មទណ្ឌនានាដែលមានចរិតលក្ខណៈអន្តរជាតូបនីយកម្ម ចំពោះការចូលរួមរបស់ជនរងគ្រោះ។ ទោះបីជាកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មិនបានចែងអំពីការចូលរួមរបស់ជនរងគ្រោះក្តី មាត្រា ៣៦ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានបើកឱកាសនេះដោយចែងអំពីសិទ្ធិក្នុងការប្តឹងសាទុក្ខរបស់ជនរងគ្រោះ។ ហេតុដូច្នេះ វិធានផ្ទៃក្នុងបានតាក់តែងក្របខ័ណ្ឌគតិយុត្ត ដោយបង្កើតជាគំរូនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបានធ្វើកែសម្រួលតាមតថភាពជាក់ស្តែងផ្នែកនីតិវិធី ក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ។ កត្តាជំរុញមួយ នៃប្រព័ន្ធដែលបានកែសម្រួលនេះ គឺភាពចាំបាច់ក្នុងការគ្រប់គ្រងការចូលរួម ការធ្វើជាតំណាង និងដំណើរការផ្តល់សំណងចំពោះជនរងគ្រោះជិត៤០០០នាក់ នៅក្នុងសំណុំរឿង ០០២។ ការអនុញ្ញាតឱ្យជនរងគ្រោះម្នាក់ៗ និងអ្នកតំណាងផ្លូវច្បាប់របស់គាត់ ឡើងថ្លែងនៅក្នុងតុលាការដោយលម្អិត ឬយ៉ាងវែងនោះ ជាសារវន្តនឹងធ្វើឱ្យកិច្ចដំណើរការនីតិវិធីតុលាការកាន់តែពន្យារពេល ដោយមិនសមហេតុផល។ ការសម្រេចលើបណ្តឹងរដ្ឋប្បវេណី (និងសំណើសុំសំណងជាបុគ្គល) ៤០០០ គឺជាការងារដែលចំណាយពេលវេលាច្រើន ហើយមិនអាចធ្វើទៅបានឡើយ ក្នុងពេលវេលា "សមស្រប"។

គំរូត្រូវបានកែលម្អឡើងជាច្រើនលើកច្រើនសា នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធី រហូតមានការពង្រឹងនូវគំរូនៃការចូលរួម ការធ្វើជាតំណាង និងសំណងរបស់ជនរងគ្រោះ ដែលមានលក្ខណៈពិសេសដូចបច្ចុប្បន្ននេះ។ ទាំងបុព្វហេតុ (ដែលមិនជាល្អឥតខ្ចោះ) និងលទ្ធផលពិសេសនៃដំណើរការនេះ គឺមិនធ្លាប់មានពីមុនមកឡើយ នៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ។

ហេតុដូច្នេះគឺជាការសមស្របដែល អ.វ.ត.ក ត្រូវនាំមុខសាជាថ្មី ក្នុងការបង្កើតក្របខ័ណ្ឌ សម្រាប់ដោះស្រាយជាមួយជនរងគ្រោះ នៅក្នុងដំណាក់កាលនៅសេសសល់ នៃតុលាការព្រហ្មទណ្ឌនានាដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម។ គោលដៅគួរតែជាការទូទាត់ចំពោះ ភាពអវិជ្ជមានខ្លះ ដូចដែលជនរងគ្រោះបានមើលឃើញ ដែលកើតចេញពីការកម្រិតកំណត់ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដូចបានរៀបរាប់ពីខាងលើ។ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ តួនាទីរបស់ជនរងគ្រោះ ថាតើពួកគេចូលរួមក្នុងនាមជាសាក្សី ឬជាភាគីបានបញ្ចប់នៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធីតុលាការ។ ប៉ុន្តែសម្រាប់ជនរងគ្រោះវិញ ការចូលរួមរបស់ពួកគាត់ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ មិនមែនជាការប្រឈមជាលើកដំបូងទៅនឹងផលវិបាកនៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តមកលើពួកគាត់នោះទេ ហើយវាក៏មិនបញ្ចប់

ហេតុដូច្នេះគឺជាការសមស្របដែល អ.វ.ត.ក ត្រូវនាំមុខសាជាថ្មី ក្នុងការបង្កើតក្របខ័ណ្ឌ សម្រាប់ដោះស្រាយជាមួយជនរងគ្រោះ នៅក្នុងដំណាក់កាលនៅសេសសល់ នៃតុលាការព្រហ្មទណ្ឌនានា ដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម។



ដូនជីតម្រង់ជួរនៅ អ.វ.ត.ក ដើម្បីចូលរួមស្តាប់សវនាការក្នុងសំណុំរឿង ០០២/០១

នៅត្រឹមនេះដែរ។ នេះគឺជាដំណាក់កាលមួយ ក្នុងដំណើរដ៏វែងឆ្ងាយរបស់ពួកគាត់ ចាប់ពីឧក្រិដ្ឋកម្មរហូតដល់ការជាសះស្បើយ។ ដោយពិចារណាថា ដំណើរការបានឆ្លុះឡើងវិញនូវមុខរបួសចាស់នោះ ជាញឹកញាប់ដំណើរការនេះ គឺជាដំណើរការដ៏លំបាក។

តាមទស្សនៈទូលាយ ការផ្សះផ្សាក្នុងទ្រង់ទ្រាយធំបំផុតនោះពោលគឺ ការផ្សះផ្សាជាតិ ត្រូវបានលើកឡើងជាញឹកញាប់ ថាជាលទ្ធផលដែលចង់បានចេញពីដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ។ ប៉ុន្តែការពិតគឺថា កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមិនបានរៀបចំឡើងសម្រាប់ការផ្សះផ្សា (ជាតិ) ទេ ហើយបើបាន ក៏មិនបានច្រើនជាចម្បងដែរ។ គោលដៅរបស់កិច្ចដំណើរការនីតិវិធីគឺ កំណត់នូវការទទួលខុសត្រូវដោយបញ្ជាក់បំភ្លឺលើការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលវេលាដ៏សមស្របមួយ។

ហេតុដូច្នេះវាហាក់ដូចជាថា ដំណាក់កាលនៅសេសសល់របស់តុលាការទទួលស្គាល់ដោយខ្លួនឯងថា ជាការចូលរួមចំណែកដល់ដំណើរការព្យាបាលរបួសស្នាមរបស់ជនរងគ្រោះនិងការជំរុញជាទ្រង់ទ្រាយធំ ដល់ការផ្សះផ្សាជាតិ។

គោលដៅទាំងពីរតម្រូវឱ្យមានការចូលរួមពីផ្នែកជាច្រើនរបស់សង្គម រួមទាំងជនរងគ្រោះទាំងឡាយណា ដែលមិនបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធី កូនចៅរបស់ពួកគាត់ ចារីកម្រិតទាប និងសាធារណជន។ ដោយសារតែការលំបាកផ្នែកច្បាប់ និងនីតិវិធីនៃកិច្ចដំណើរការនីតិវិធី

ហេតុដូច្នេះវាហាក់ដូចជាថា ដំណាក់កាលនៅសេសសល់របស់តុលាការទទួលស្គាល់ដោយខ្លួនឯងថា ត្រូវចូលរួមចំណែកដល់ដំណើរការព្យាបាលរបួសស្នាមរបស់ជនរងគ្រោះ និងជំរុញជាទ្រង់ទ្រាយធំ ដល់ការផ្សះផ្សាជាតិ។

"អ្នកដែលមិនចងចាំអតីតកាល ងាយនឹងដើរជាន់សាជាថ្មី"

George Santayana

ព្រហ្មទណ្ឌ លែងមានទៀតហើយក្នុងដំណាក់កាលនេះ ការចូលរួមជាទ្រង់ទ្រាយធំបែបនេះ គឺអាចធ្វើទៅបាន។ បន្ថែមលើនេះ គឺជាការចាំបាច់ដោយសារតែការគាំទ្រចំពោះជនរងគ្រោះ និងជាពិសេសនោះគឺការផ្សះផ្សាជាតិ ទាមទារឱ្យមានវិធីសាស្ត្រជារួមមួយ សម្រាប់ដោះស្រាយជម្លោះបន្ថែមពីលើអ្វីដែលការជំនុំជម្រះព្រហ្មទណ្ឌអាចផ្ដល់ឱ្យ។ សមាជិកសង្គមទាំងអស់ គឺសុទ្ធតែទទួលរងផលប៉ះពាល់ នៅពេលមានជម្លោះ ដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការ ហើយផលវិបាកនៃជម្លោះនោះគឺនៅបន្តរហូតនិងនៅតែមានឥទ្ធិពលរហូតមកដល់ពេលនេះ។ ពាក់កណ្ដាល នៃប្រជាជនកម្ពុជាបច្ចុប្បន្ន គឺកើតក្រោយរបបខ្មែរក្រហម ប៉ុន្តែពួកគេទទួលរងផលពីការប៉ះទង្គិច ដែលឪពុកម្ដាយ សាច់ញាតិ និងជនរួមជាតិរបស់ពួកគេ បានទទួលរង និងផលវិបាកសង្គមជាទ្រង់ទ្រាយធំ ដែលបន្តមក។ ការយល់ដឹងអំពីចំណុចអកុសល នៃប្រវត្តិសាស្ត្ររបស់ប្រទេសពួកគេ គឺជារឿងចាំបាច់។

ដូចសុភាសិតមួយដ៏ល្បីដែលលើកឡើងថា៖ "អ្នកដែលមិនចងចាំអតីតកាល ងាយនឹងដើរជាន់សាជាថ្មី" (George Santayana)។

លក្ខណៈពិសេសមួយទៀតនៃការកត់សម្គាល់ នៅក្នុងបរិបទនេះ គឺថា អ.វ.ត.ក ជាតុលាការចម្រុះ។ លក្ខណៈនេះពង្រីកទៅដល់សមាសភាពនៃអង្គជំនុំជម្រះ បុគ្គលិក និងអ្នកតំណាងភាគី ព្រមទាំងក្របខ័ណ្ឌ គតិយុត្តិ។ ការកសាងសមត្ថភាព និងការផ្ទេរចំណេះដឹង តាមរយៈកិច្ចសហប្រតិបត្តិការ គឺជាកត្តាជំរុញយ៉ាងច្បាស់ សម្រាប់តុលាការចម្រុះទាំងអស់។ ការបន្តលក្ខណៈនេះ រហូតដល់ដំណាក់កាលនៅសេសសល់ និងលើសពីកម្រិតតូចចង្អៀតនៃជំនាញផ្លូវច្បាប់នោះ គឺជាកិច្ចខិតខំប្រឹងប្រែងប្រកបដោយគុណតម្លៃ។

ដំណើរការផ្ទេរចំណេះដឹង នៅក្នុងផ្នែកផ្សេងពីច្បាប់ បានចាប់ផ្ដើមនៅដំណាក់កាលទូទាត់សំណង ដែលរួមមានគម្រោងនានា ទាក់ទងនឹងបញ្ហាដូចជា សុខភាពផ្លូវចិត្ត ជាផ្នែកមួយនៃប្រព័ន្ធសុខាភិបាលជាតិ ដែលមានផ្នែកត្រូវកែលម្អ សន្ទានកម្ម ជាជំនាញដែលអាចអនុវត្តបានយ៉ាងទូលំទូលាយនៅតាមវិស័យផ្សេងគ្នាជាច្រើន និង ការផ្សះផ្សា ជាដំណើរការកំពុងតែបន្តនៅក្នុងសង្គមកម្ពុជាទំនើបបច្ចុប្បន្ន។ យើងកត់សម្គាល់ថា គម្រោងជាច្រើនដែលបានផ្ដល់ឱ្យ សម្រាប់ដំណាក់កាលនៅសេសសល់ បានបង្កើតឡើងផ្អែកលើគម្រោងសំណងទាំងអស់នោះ ហេតុដូច្នេះវាមានលទ្ធភាពអនុញ្ញាតឱ្យមានការពង្រីកលទ្ធផលនិងការបង្កើតគំនិតផ្ដួចផ្ដើមប្រកបដោយនិរន្តរភាព។ គំនិតផ្ដួចផ្ដើមខ្លះគួរតែដំណើរការដោយល្អ នៅដំណាក់កាលនៅសេសសល់ ហើយបន្តផ្ដល់ផលប្រយោជន៍មិនត្រឹមតែជនរងគ្រោះផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅដល់ផ្នែកដ៏ធំនៃប្រជាជនទាំងអស់។

គួរឱ្យកត់សម្គាល់នៅក្នុងបរិបទនេះគឺថា តុលាការដទៃតែមួយ ដែលជាតុលាការព្រហ្មទណ្ឌមានចរិតលក្ខណៈអន្តរជាតូបនីយកម្ម ហើយ ដែលមានគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងជនរងគ្រោះនៅដំណាក់កាលនៅសេសសល់(តុលាការ SCSL) ក៏ជាតុលាការចម្រុះ ដែលស្ថិតនៅក្នុងតំបន់ជម្លោះ។ ទីតាំងជិតគ្នារវាងតុលាការ និងជនរងគ្រោះ ហាក់ដូចជាកត្តាកំណត់ សម្រាប់ឱ្យភាគីទាំងពីរ មានការពាក់ព័ន្ធបន្ថែមទៀត។

នេះគឺជាការពិតមួយដែលត្រូវធ្វើការពិចារណា នៅពេលគ្រោងបង្កើតតុលាការព្រហ្មទណ្ឌដែលមាន ចរិតលក្ខណៈអន្តរជាតូបនីយកម្ម ដទៃទៀត។

ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមទស្សនាពិព័រណ៍ចល័ត ស្តីពី ជនរងគ្រោះនៃរបបខ្មែរក្រហម នៅសៀមរាប



# ការពិភាក្សាអំពីសំណើ

ដើម្បីតម្លាភាពនិងដោយមានការយល់ព្រមពីអ្នកចូលរួម យើងបានភ្ជាប់ឧបសម្ព័ន្ធនូវសំណើពាក់ព័ន្ធទាំងអស់មកជាមួយ។

ការណ៍នេះអនុញ្ញាតឱ្យអ្នកអានជ្រាបអំពីសេចក្តីលម្អិតនៃគំនិតទាំងឡាយដែលត្រូវបានសង្ខេបរួមខាងក្រោម។ ការពិភាក្សានេះកំណត់អត្តសញ្ញាណប្រភពនៃអនុសាសន៍ អ្នកចូលរួម និងផ្តល់ជារួមនូវទិដ្ឋភាពទូទៅនៃលក្ខណៈ និង វិសាលភាពនៃគំនិត។

ជាងនេះទៀត ការពិភាក្សានេះអាចផ្តល់ជាការលើកទឹកចិត្តសម្រាប់ការដាក់សំណើថ្មីៗដែលអនុញ្ញាតឱ្យរកឃើញគំនិតដែលបានរំលងនិងផ្តល់ជម្រើសសម្រាប់សំយោគបន្ថែមទៀត។

យើងកត់សម្គាល់ថាកាលបរិច្ឆេទសម្រាប់ទទួលរបាយការណ៍ និងពេលវេលាសម្រាប់ផ្តល់សំណើគឺនៅពេលខ្លីនិងអ្នកពាក់ព័ន្ធមានការ ភ្ញាក់ផ្អើលចំពោះការស្នើសុំរបស់យើងឱ្យមានការចូលរួម។

គ្មានអ្វីគួរឱ្យសង្ស័យទេថាការណ៍នេះ គឺពិតជាធ្វើឱ្យសំណើបច្ចុប្បន្នបានវិវឌ្ឍដល់កាលផ្សេងៗគ្នា។ សំណើទាំងនោះ មានចាប់តាំងពីគំនិតគោលៗរហូតដល់គម្រោងដែលមានលក្ខណៈពេញលេញ។ សំណើខ្លះអាចទទួលប្រយោជន៍ពីការជួយរបស់អ្នកជំនាញក្នុងការកសាងគម្រោង។ ក្នុងបរិបទនេះ យើងកត់សម្គាល់ថាកម្មវិធី GIZ-CPS បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រ អ.រ.ត.ក ជាពិសេសនៅក្នុងវិស័យការងារពាក់ព័ន្ធជនរងគ្រោះ ឧទាហរណ៍ ការផ្តល់ជំនាញឯកទេសក្នុងការបង្កើតគម្រោង។ ផ្អែកលើការតាំងចិត្តដ៏លេចធ្លោរពេញមួយជីវិតសាលាក្តីកន្លងមក យើងស្នើឱ្យមានការដកបទពិសោធន៍ពីពួកគេនិងពីបណ្តាញដ៏ទូលំទូលាយរបស់ពួកគេ នៅក្នុងដំណាក់កាលនេះដែរ។

សំណើដែលយើងបានទទួលមានជាចម្បងៗ ដូចមានខាងក្រោម៖

- គោលការណ៍ណែនាំសម្រាប់គំនិតផ្ដួចផ្ដើមពាក់ព័ន្ធនឹងជនរងគ្រោះនៅក្នុងដំណាក់កាលដែលនៅសេសសល់
- ការអប់រំ (សាលារៀន សាកលវិទ្យាល័យ) អំពីយុត្តិធម៌អន្តរកាល និង អ.វ.ត.ក
- ព័ត៌មាននៃ/ទៅកាន់សាធារណជនទូទៅអំពី អវតក (ដូចជាការតាំងពិព័រណ៍ បាឋកថា ទស្សនកិច្ចសិក្សា កម្មវិធីពិភាក្សាតាមវិទ្យុ និង វេបសាយ)
- ការរៀបចំទិន្នន័យ ការវាយតម្លៃ និង ការអភិរក្ស
- ការផ្សះផ្សាសហគមន៍ សក្ខីកម្ម សន្ទានកម្ម/ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- គំនិតផ្ដួចផ្ដើមសុខភាពផ្លូវចិត្ត
- ការសិក្សាស្រាវជ្រាវក្នុងវិស័យនានា
- វិមានរំឮក ចេតិយ ពិធីបុណ្យផ្សេងៗ




ព្រះសង្ឃសូត្រមន្តប្រោសព្រំដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមទិវាចងចាំថ្ងៃទី២០ ខែឧសភា ដែលប្រារព្ធធ្វើនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

អ្វីដែលមិនស្ថិតនៅក្នុងសំណើណាមួយ ប៉ុន្តែមានតម្លៃគួរពិចារណានៅក្នុងទស្សនៈរបស់យើងគឺការបង្កើតសេវាគាំពារជនរងគ្រោះនៅក្នុងប្រព័ន្ធច្បាប់ព្រហ្មទណ្ឌជាតិ។ សេវាទាំងនេះរួមមាន សេវាជាពិសេសទោះបីជាមិនផ្តាច់មុខ សម្រាប់ជនរងគ្រោះនៃបទល្មើសពាក់ព័ន្ធផ្លូវភេទ និង ជនជាតិភាគតិច ក្នុងនោះរួមមានការគាំទ្រច្បាប់ ហិរញ្ញវត្ថុ និង ចិត្តសាស្ត្រ។

គម្រោងនានាពាក់ព័ន្ធនឹងការផ្ទេរចំណេះដឹងក្នុងវិស័យច្បាប់ ក្នុងចំណោមបញ្ហាផ្សេងទៀត ការបណ្តុះបណ្តាល ចៅក្រម ព្រះរាជអាជ្ញា និង មេធាវី គួរតែត្រូវពិចារណា។

ការចងក្រងអត្ថបទស្រាវជ្រាវដ៏ច្រើនសន្ធឹកសន្ធាប់អំពី អ.វ.ត.ក អាចផ្តល់នូវឧបករណ៍ដ៏មានតម្លៃសម្រាប់សកម្មភាពស្រាវជ្រាវបន្ថែមទៀត។

ការចងក្រងអត្ថបទសារព័ត៌មានដាច់ដោយឡែកអំពី អ.វ.ត.ក ក្នុងរយៈពេលនៃការងារអាចជាការឆ្លុះបញ្ចាំងដ៏គួរឱ្យចាប់អារម្មណ៍លើទស្សនទានសាធារណៈរបស់តុលាការនេះក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក។

ផ្អែកលើការកម្រិតដូចបានរៀបរាប់ខាងលើពាក់ព័ន្ធនឹងដំណាក់កាលនៃគំនិតផ្តួចផ្តើមនេះ និងកម្រិតនៃការអភិវឌ្ឍគំនិត ការវិភាគស៊ីជម្រៅឬការវាយតម្លៃ គឺមិនអាចធ្វើទៅបាននៅពេលនេះទេ។

ប៉ុន្តែ ក្នុងចំណោមអនុសាសន៍ទូទៅដែលយើងទទួលបាន យើងយល់ស្របទៅលើអនុសាសន៍ដូចខាងក្រោម៖

- គំនិតផ្តួចផ្តើមណាមួយត្រូវតែផ្តល់អាទិភាពដល់គោលការណ៍ "មិនប៉ះពាល់"។ ការធ្វើឱ្យជនរងគ្រោះប៉ះទង្គិចអារម្មណ៍សាជាថ្មីត្រូវតែចៀសវាងហើយឯកជនភាពរបស់ពួកគាត់ត្រូវតែគោរព។ ចំពោះអង្គការបរទេសដែលចូលរួមក្នុងគម្រោងក្នុងប្រទេស ព័ត៌មានអំពីបរិបទកម្ពុជាគួរតែសង្កេតដោយយកចិត្តទុកដាក់។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ការចូលរួមរបស់តំណាងរបស់ពួកគាត់ នឹងមានគុណប្រយោជន៍។

- គម្រោងដែលបង្កើតឡើងនៅលើគំនិតផ្តួចផ្តើមពីមុនឬដែលមានស្រាប់គួរតែផ្តល់អាទិភាព

- កិច្ចសហប្រតិបត្តិការរវាងការស្រាវជ្រាវនិងគម្រោងសហគមន៍គួរតែជំរុញ

- ការបង្រួមចូលគ្នា ការអភិរក្ស និង ការបោះពុម្ពផ្សាយព័ត៌មានអំពីសកម្មភាពពាក់ព័ន្ធជរងគ្រោះ (គម្រោង គំនិតផ្តួចផ្តើម ។ល។) ដែលត្រូវបានអនុវត្តមកដល់ពេលនេះគួរតែអនុវត្តឱ្យបានឆាប់តាមតែអាចធ្វើទៅបានក្នុងគោលបំណងធានាថាចំណេះដឹងដែលត្រូវបានដកស្រង់ និង ព័ត៌មានមិនបាត់បង់។ ការណ៍នេះក៏អាចចៀសវាងកិច្ចប្រឹងប្រែងស្ទួនលើគ្នាផងដែរ។

យើងកត់សម្គាល់ថា សំណើមួយចំនួនមានការពាក់ព័ន្ធលើបញ្ហាបណ្ណសារ។ ប៉ុន្តែបញ្ហានេះគឺស្ថិតនៅក្រៅអាណត្តិនៃរបាយការណ៍នេះ។

# អនុសាសន៍អំពីដំណើរឆ្ពោះទៅមុខ

**តាមរយៈការសម្រេចថា តើត្រូវដំណើរការរបៀបណានោះ គឺត្រូវរក្សាតុល្យភាពរវាងសន្ទុះដែលបង្កើតដោយការស្នើសុំការចូលរួមនិងការអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធមានពេលវេលាគ្រប់គ្រាន់ក្នុងការដាក់គំនិតថ្មី អភិវឌ្ឍគំនិតដែលមានស្រាប់ ហើយនៅពេលដែលអាចអនុវត្តបាននោះ គឺស្វែងរកថាមពលរួមដោយសហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀត។**

ព័ត៌មានតបដែលយើងទទួលបានក្នុងអំឡុងដំណើរការនេះបានបង្ហាញថាគំនិតផ្តួចផ្តើមនេះធ្វើឱ្យមនុស្សភាគច្រើនភ្ញាក់ផ្អើលនៅពេលដែលអ្នកពាក់ព័ន្ធជាច្រើនស្ថិតក្នុងដំណើរការប្តូរទិសដៅធ្វើផែនការក្នុងនោះរួមមានការផ្តល់ថវិកាក្រៅក្របខ័ណ្ឌ អ.វ.ត.ក។ ចំណាប់អារម្មណ៍ទូទៅដែលយើងទទួលបានគឺថាការចូលរួមរបស់តុលាការជាមួយនឹងជនរងគ្រោះអាចកាត់បន្ថយនៅចុងកិច្ចនីតិវិធីតុលាការ។ គំនិតដែលថាតុលាការអាចចូលរួមជាមួយជនរងគ្រោះនៅក្នុងដំណាក់កាលសេសសល់គឺជារឿងថ្មី និងជាទស្សនទានមិនធ្លាប់មានពីមុនមកក្នុងប្រវត្តិសាស្ត្រតុលាការព្រហ្មទណ្ឌដែលមានចរិតលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម លើកលែងតែតុលាការពិសេសសម្រាប់ប្រទេសសេ រ៉ាឡេអូនតែប៉ុណ្ណោះ។ សុពលភាពនៃគំនិតនេះត្រូវបានទទួលស្គាល់ដោយអ្នកពាក់ព័ន្ធជាច្រើននៅក្នុងព័ត៌មានតប និង តាមរយៈការចូលរួមជាមួយគំនិតផ្តួចផ្តើម។ កត្តាភ្ញាក់ផ្អើលជាមួយពេលវេលាខ្លីសម្រាប់ដាក់សំណើនោះបង្ហាញថាគំនិតជាច្រើនដែលបានស្នើឡើងគឺកំពុងស្ថិតនៅដំណាក់កាលដំបូង។ កត្តានេះក៏ពន្យល់ផងដែរអំពីសំណើនានារបស់អង្គការឬបុគ្គលជាច្រើនដែលមានចំណាប់អារម្មណ៍ក្នុងការដាក់ជូនគំនិតនានាក្រោយកាលបរិច្ឆេទកំណត់។ យើងបានបញ្ជាក់ជម្រើសនេះនៅពេលទទួលសំណួរនេះ និង បានពិចារណាលើការដាក់សំណើយឺតពេល។

សង្ខេប ៖

របាយការណ៍ប្រឹក្សានេះនិងសកម្មភាពនានានាំទៅដល់ការធ្វើរបាយការណ៍នេះ ត្រូវចាត់ទុកជាចំណុចចាប់ផ្តើមនៃដំណើរការដ៏វែងឆ្ងាយដែលទើបចាប់ផ្តើម ។ តាមរយៈការសម្រេចថា តើត្រូវដំណើរការរបៀបណានោះ គឺត្រូវរក្សាតុល្យភាពរវាងសន្ទុះដែលបង្កើតដោយការស្នើសុំការចូលរួម និង ការអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធមានពេលវេលាគ្រប់គ្រាន់ក្នុងការដាក់គំនិតថ្មី អភិវឌ្ឍគំនិតដែលមានស្រាប់ ហើយនៅពេលដែលអាច អនុវត្តបាននោះ គឺស្វែងរកថាមពលរួមដោយសហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀត។

ជាជំហានដំបូង យើងស្នើបោះពុម្ពផ្សាយរបាយការណ៍នេះនិងស្នើជួបគ្នារវាងភាគីពាក់ព័ន្ធបច្ចុប្បន្ន ក្នុងនោះរួមមានអ្នកចូលរួមគំនិតផ្តួចផ្តើមនេះ និង អ.វ.ត.ក ដែលតំណាងដោយការិយាល័យរដ្ឋបាលនៅចុងខែមករា ឆ្នាំ២០២២ ជាការល្អ។ ដោយសារតែការរិតបន្តឹងលើបញ្ហាកូវីដ-១៩ ត្រូវបានបន្ធូរបន្ថយ ចំណុចពេលវេលានេះគួរតែអាចធ្វើទៅបាន។ ការជួបប្រជុំនេះនឹងបង្ហាញឱ្យឃើញនូវភាពច្បាស់លាស់នៃគំនិតផ្តួចផ្តើមនេះ ជាអ្វីដែលភាគីពាក់ព័ន្ធមួយចំនួននៅតែមានមន្ទិល។ ការជួបប្រជុំនេះក៏នឹងបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្តរបស់ការិយាល័យរដ្ឋបាលដែលទទួលបន្ទុកក្នុងការរៀបចំ និងត្រួតពិនិត្យលើការងារនៃដំណាក់កាលសេសសល់ ដែលក្នុងនោះរួមមានផ្នែកពាក់ព័ន្ធនឹងជនរងគ្រោះផងដែរ។ ការជួបប្រជុំនេះនឹងអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធបំភ្លឺបញ្ជាក់វិធីងាយស្រួលមួយ



សិស្សានុសិស្សនៅសាលាអន្លង់វែង ស្ដាប់ការពន្យល់រៀបរាប់ពីផ្នែកកិច្ចការសាធារណៈ អំពីការវិវឌ្ឍន៍នៅ អ.វ.ត.ក

និង ដោយផ្ទាល់នូវបញ្ហាទាំងឡាយពាក់ព័ន្ធនឹងទំនាក់ទំនងរវាង អ.វ.ត.ក និង ភាគីពាក់ព័ន្ធ ពេលវេលាកំណត់ និង ថវិកា។ល។

បច្ចុប្បន្នមានភាពមិនច្បាស់លាស់ជាច្រើនអំពីបញ្ហាទាំងនេះ ដែលនឹងជះឥទ្ធិពលដោយផ្ទាល់ទៅលើឆន្ទៈ និងសមត្ថភាពរបស់ភាគីពាក់ព័ន្ធទាំងនេះក្នុងការចូលរួមបន្ថែមទៀត។ ទោះបីជាភាពបត់បែនក្នុងអំឡុងដំណើរការនេះនឹងមានសារៈសំខាន់ក៏ដោយ ក៏ភាគីពាក់ព័ន្ធចាំបាច់ត្រូវការការបញ្ជាក់បំភ្លឺបន្ថែមលើលើបញ្ហាទាំងនេះមួយចំនួន។

ការិយាល័យរដ្ឋបាលនឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចប្រជុំនេះ ដោយសារបានដឹងពីដំបូងអំពីឧបសគ្គដែលអាចកើតឡើង ហើយប្រសិនបើមិនអាចដោះស្រាយបានទាន់ពេលនោះទេ វាអាចរារាំងដល់ការអនុវត្តឱ្យបានជោគជ័យ។

ដោយសារថា តាមការរំពឹងទុក ភាគីពាក់ព័ន្ធនឹងមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ យើងគួរជៀសវាងបញ្ហាច្រំដែលៗ។ កិច្ចប្រជុំនេះក៏អាចជាវេទិកាមួយសម្រាប់ភាគីពាក់ព័ន្ធចូលរួមជាមួយគ្នា ដើម្បីរិះរកវិធីពូនជាកម្លាំង រួមគ្នាអនុវត្តគម្រោងនានា។

**របាយការណ៍ប្រឹក្សានិងសកម្មភាពនានានាំទៅដល់ការធ្វើរបាយការណ៍នេះត្រូវចាត់ជាចំណុចចាប់ផ្តើមនៃដំណើរការដ៏វែងឆ្ងាយដែលទើបចាប់ផ្តើម។**

យើងសូមស្នើឱ្យមានការប្រជុំស្រដៀងគ្នាជារៀងរាល់ ០៣ ខែម្តង ដើម្បីរៀបចំដាក់សំណើគ្រប់ជ្រុងជ្រោយ ឱ្យរួចរាល់ក្នុងរយៈពេល ០៦ ខែ ក្រោយកិច្ចប្រជុំ។

យើងសូមស្នើបន្ថែមទៀតឱ្យពិនិត្យមើល ដំណាក់កាលមុនពេលអនុវត្តមុខងារដែលនៅសេសសល់ ដើម្បីពិនិត្យលទ្ធភាពមើលថា តើគម្រោងមួយចំនួនណាខ្លះអាចចាប់ផ្តើមបាន។ ឧទាហរណ៍ ការធ្វើដូច្នេះអាចឱ្យយើងបន្តការងារគម្រោងដោយរលូន ដូចការងារតាមដានចំពោះគំនិតផ្តួចផ្តើម ដែលយើងបាន និងកំពុងធ្វើឡើង។

យើងក៏សូមផ្តល់អនុសាសន៍ជូនការិយាល័យរដ្ឋបាល ឱ្យបង្កើតមិនត្រឹមតែយុទ្ធសាស្ត្រទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ និងម្ចាស់ជំនួយប៉ុណ្ណោះទេ ប៉ុន្តែឱ្យបង្កើតទំនាក់ទំនងបន្ថែមជាមួយប្រព័ន្ធផ្សព្វផ្សាយ ដែលអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាញគំនិតផ្តួចផ្តើម និងទស្សនាទានសំខាន់ៗជូនដល់សាធារណជន។ ការដឹងឮបានទូលំទូលាយអំពីគំនិតផ្តួចផ្តើមនេះក៏នឹងអាចជួយដល់ការងាររៃអង្គាសថវិកាផងដែរ។ ទោះបីជាកន្លងមក ធ្លាប់មានទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយក៏ដោយ ក៏យើងនៅមិនទាន់បានធ្វើទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ ដើម្បីកុំឱ្យមានការផ្សព្វផ្សាយដោយបុរេនិច្ឆ័យលើការងារ អភិវឌ្ឍបន្តនេះ នៅក្នុងដំណាក់កាលចាប់ផ្តើមនៃគំនិតផ្តួចផ្តើមនេះនៅឡើយទេ។

> **ល្អបំផុតនោះ គម្រោងមួយចំនួនអាចត្រូវឱ្យមានការខិតខំប្រឹងប្រែងរយៈពេលវែង ដែលនៅមានក្នុងពេលអត្ថិភាពនៃតុលាការ រួមទាំងក្នុងដំណាក់កាលដែលនៅសេសសល់របស់តុលាការទៀតផង។**

ល្អបំផុតនោះ គម្រោងមួយចំនួនអាចត្រូវឱ្យមានការខិតខំប្រឹងប្រែងរយៈពេលវែង ដែលនៅមានក្នុងពេលអត្ថិភាពនៃតុលាការ រួមទាំងក្នុងដំណាក់កាលដែលនៅសេសសល់របស់តុលាការទៀតផង។ ដើម្បីធានាបាននូវនិរន្តរភាព យើងចាំបាច់ត្រូវរៀបចំផ្ទេរតាមពេលវេលាសមស្របមួយនូវ ការគ្រប់គ្រងនៃគំនិតផ្តួចផ្តើមទាំងនេះ ឱ្យទៅស្ថាប័នអចិន្ត្រៃយ៍ណាមួយដែលទទួលការផ្គត់ផ្គង់មូលនិធិចេញពីថវិការបស់រដ្ឋ ដើម្បីកាត់បន្ថយការពឹងផ្អែកលើម្ចាស់ជំនួយនាពេលអនាគត។ ក្នុងបរិបទនេះមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់អាចជាស្ថាប័នសមស្របមួយ ក្នុងការគ្រប់គ្រងការងារនេះ។

ជារួម យើង៖

- សូមកោតសរសើរដល់ការិយាល័យរដ្ឋបាលចំពោះការចាប់ផ្តើមដំណើរការនេះ ដែលមានសក្តានុពលដើម្បីបង្កើតនូវយុត្តិសាស្ត្រជោគជ័យមួយសម្រាប់តុលាការអន្តរជាតិនានា នាពេលអនាគត។

- សូមអរគុណភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកដ៏មានតម្លៃ និង

- សូមលើកទឹកចិត្តភាគីពាក់ព័ន្ធផ្សេងទៀត ឱ្យចូលរួមចំណែកក្នុងដំណើរការនេះ។ ដំណាក់កាលថ្មី ដ៏គួរឱ្យចាប់អារម្មណ៍នៅក្នុងប្រវត្តិសាស្ត្រនៃ អ.វ.ត.ក បានចាប់ផ្តើមបើកចំហចាប់ពីពេលនេះតទៅ។

**សូមឱ្យគំនិតផ្តួចផ្តើមនេះទទួលបានជោគជ័យទៅតាមបំណង។**

# ឧបសម្ព័ន្ធ ១
# កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិស្តីអំពី អ.វ.ត.ក

# កិច្ចព្រមព្រៀងបន្ថែម
# នៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ
# ទាក់ទងនៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម
# ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
# ស្តីពី
# ការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ

ដោយរម្លឹកអំពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ នៅរាជធានីភ្នំពេញ (តទៅនេះហៅថា "កិច្ចព្រមព្រៀង")

ដោយហេតុថា ភាគីនៃ"កិច្ចព្រមព្រៀង"យល់ព្រមគ្នាថា ក្រោយពីការបញ្ចប់រាល់កិច្ចដំណើរការនីតិវិធីតុលាការអនុលោមតាមមាត្រា១នៃ"កិច្ចព្រមព្រៀង" អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តការងារសេសសល់សំខាន់ៗមួយចំនួនដូចមានកំណត់នៅក្នុងកិច្ចព្រមព្រៀងបន្ថែមនេះ

ដោយហេតុថា ភាគីនៃ"កិច្ចព្រមព្រៀង"ជឿជាក់ថា ដោយយោងទៅដល់លក្ខណៈកាត់បន្ថយយ៉ាងធំធេងនៃមុខងារសេសសល់ អង្គជំនុំជម្រះវិសាមញ្ញគួរមានចំនួនបុគ្គលិកដែលសមាមាត្រជាមួយនឹងមុខងាររបស់ខ្លួនដែលត្រូវបានកាត់បន្ថយនោះ

ដោយហេតុថា ភាគីនៃ"កិច្ចព្រមព្រៀង"បានធ្វើការពិភាក្សាគ្នាស្តីពីការរៀបចំក្នុងពេលអន្តរកាលសម្រាប់ការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញនិងការបំពេញមុខងារសេសសល់

អាស្រ័យហេតុនេះ ក្នុងពេលនេះ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាដូចខាងក្រោម៖

## មាត្រា ១

## ការរៀបចំក្នុងពេលអន្តរកាល

ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះនេះត្រូវលែងមានការិយាល័យនៅអង្គជំនុំជម្រះវិសាមញ្ញទៀតហើយ។ បន្ទាប់ពីលែងមានការិយាល័យនៅអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមទាំងអស់ត្រូវទទួលបានបៀវត្សរ៍ដោយសមាមាត្រទៅនឹងការងារ ហើយត្រូវបំពេញការងារពីចម្ងាយលើកលែងតែនៅពេលដែលតម្រូវឱ្យមានវត្តមាននៅអង្គជំនុំជម្រះវិសាមញ្ញទៅតាមសំណើរបស់ប្រធានអង្គជំនុំជម្រះប៉ុណ្ណោះ។

## មាត្រា ២

## មុខងារសេសសល់

១. ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធីដោយអនុលោមតាមមាត្រា១នៃ"កិច្ចព្រមព្រៀង" រួមទាំងបណ្តឹងសាទុក្ខណាមួយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះវិសាមញ្ញត្រូវបន្តបំពេញមុខងារនានាសម្រាប់រយៈពេលបីឆ្នាំដំបូង ដូចតទៅ៖ ពិនិត្យមើលទៅលើពាក្យសុំនានានិងដំណើរការនីតិវិធីសើរើទៅលើសាលដីកាស្ថាពរ ផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ដាក់ទណ្ឌកម្មឬបញ្ជូនទៅអាជ្ញាធរពាក់ព័ន្ធនូវការជ្រៀតជ្រែកនានាដោយចេតនាក្នុងកិច្ចការរដ្ឋបាលតុលាការឬការផ្តល់សក្ខីកម្មក្លែងក្លាយ គ្រប់គ្រងការអនុវត្តទោសព្រមទាំងការតាមដានការប្រព្រឹត្តចំពោះទណ្ឌិត ថែទាំ រក្សាទុកនិងគ្រប់គ្រងបណ្ណសាររបស់ខ្លួនរួមទាំងការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឯកសារសំណុំរឿងទាំងអស់ ឆ្លើយតបទៅនឹងសំណើសុំចូលពិនិត្យមើលឯកសារ ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញ និងត្រួតពិនិត្យមើលការអនុវត្តការផ្តល់សំណងដែលបានផ្តល់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីទៅតាមករណីចាំបាច់។

២. អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវពិនិត្យមើលវឌ្ឍនភាពនៃមុខងារទាំងនេះក្រោយពេលបីឆ្នាំដំបូង បន្ទាប់មកអង្គជំនុំជម្រះវិសាមញ្ញត្រូវបន្តបំពេញមុខងារទាំងនេះឬមុខងារមួយផ្នែកក្នុងថិរវេលាដែលត្រូវកំណត់ដោយភាគីទាំងពីរ។

៣. ការស្នើសុំឱ្យសើរើនូវសាលដីកាស្ថាពរ អាចធ្វើបានតែក្នុងអំឡុងពេលដែលទណ្ឌិតនៅមានជីវិតនិងត្រូវធ្វើឡើងដោយទណ្ឌិតឬសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

៤. ប្រសិនបើទណ្ឌិតមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការបន្ធូរបន្ថយទោស ការដោះលែងមុនពេលកំណត់ឬការដោះលែងដោយមានលក្ខខណ្ឌ រាជរដ្ឋាភិបាលកម្ពុជាត្រូវជូនដំណឹងដល់អង្គជំនុំជម្រះវិសាមញ្ញអំពីស្ថានភាពនេះ។ ការបន្ធូរបន្ថយទោស ការដោះលែងមុនពេលកំណត់ឬការដោះលែងដោយមានលក្ខខណ្ឌអាចធ្វើទៅបានលុះត្រាតែអង្គជំនុំជម្រះតុលាការកំពូលជាអ្នកសម្រេចដោយផ្អែកលើផលប្រយោជន៍យុត្តិធម៌និងគោលការណ៍ទូទៅនៃច្បាប់។

៥. ចៅក្រម សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលបានបៀវត្សរ៍សមាមាត្រទៅនឹងការងារដែលបានបំពេញដូចបានកំណត់ក្នុងកថាខណ្ឌទី១ខាងលើ ហើយពួកគេត្រូវបំពេញការងារពីចម្ងាយ លើកលែងតែមុខងាររបស់ខ្លួនតម្រូវឱ្យមកបង្ហាញខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញ។ ចំពោះករណីរបស់ចៅក្រម ការមកបង្ហាញខ្លួនលុះត្រាតែមានសំណើពីប្រធានអង្គជំនុំជម្រះរបស់ខ្លួន។ កិច្ចប្រជុំពេញអង្គរបស់តុលាការត្រូវធ្វើពីចម្ងាយ ហើយការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងត្រូវសម្រេចពីចម្ងាយដោយនីតិវិធីជាលាយលក្ខណ៍អក្សរ។

៦. នៅពេលចាប់ផ្ដើមមុខងារដូចមានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវរៀបចំផ្ដល់បញ្ជីឈ្មោះបេក្ខជនចៅក្រមអន្តរជាតិបន្ថែម អនុលោមតាមកថាខណ្ឌទី៥នៃមាត្រា៣នៃ"កិច្ចព្រមព្រៀង" ដើម្បីធានាថាមានចំនួនចៅក្រមអន្តរជាតិគ្រប់គ្រាន់ដើម្បីបំពេញមុខងារទៅតាមកថាខណ្ឌទី១នៃមាត្រានេះ ក្នុងករណីដែលចៅក្រមអន្តរជាតិដែលបានតែងតាំងរួចហើយមិនអាចបំពេញមុខងាររបស់ខ្លួនបានក្នុងករណីចាំបាច់។ រាជរដ្ឋាភិបាលកម្ពុជាក៏ត្រូវរៀបចំបញ្ជីឈ្មោះបេក្ខជនចៅក្រមជាតិស្រដៀងគ្នាដែរ ដើម្បីធានាថាមានចៅក្រមជាតិមកបំពេញការងារក្នុងករណីដែលចៅក្រមជាតិដែលបានតែងតាំងរួចហើយមិនអាចបំពេញមុខងាររបស់ខ្លួនបានក្នុងករណីចាំបាច់។

## មាត្រា ៣

## បណ្ណសារ

១. អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាយល់ព្រមគ្នាថា ជាការសំខាន់ដែលធានាថាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានរក្សាទុកដោយអនុលោមតាមបទដ្ឋានអន្តរជាតិហើយសាធារណជនអាចចូលមើលបានយ៉ាងទូលំទូលាយ។

២. ក្នុងគោលបំណងដើម្បីថែរក្សានិងលើកកម្ពស់កេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញដែលជាផ្នែកនៃមុខងារសេសសល់របស់ខ្លួន អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុញ្ញាតឱ្យសាធារណជនមានសិទ្ធិចូលមើលបាននូវសំណៅអេឡិចត្រូនិក និងសំណៅជាក្រដាសនៃបណ្ណសារសាធារណៈ។

៣. អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវមានដូចគ្នានូវសំណុំបណ្ណសារពេញលេញរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលរួមបញ្ចូលនូវសំណុំឯកសារនិងសម្ភារៈទាំងអស់។ ក្រោយពេលបញ្ចប់កិច្ចដំណើរការនីតិវិធីដោយអនុលោមតាមមាត្រា១នៃ"កិច្ចព្រមព្រៀង" អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបាននូវសំណុំបណ្ណសារសាធារណៈពេញលេញ។ ក្រោយពេលបញ្ចប់មុខងារសេសសល់ដោយអនុលោមតាមមាត្រា២នៃកិច្ចព្រមព្រៀងបន្ថែមនេះ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបានឯកសារនិងសម្ភារៈសាធារណៈបន្ថែមដែលមាន ព្រមទាំងឯកសារនិងសម្ភារៈសម្ងាត់ពេញលេញ។

## មាត្រា ៤

## ការអនុម័តយល់ព្រម

ដើម្បីចងកាតព្វកិច្ចដល់ភាគី កិច្ចព្រមព្រៀងបន្ថែមនេះត្រូវទទួលការអនុម័តយល់ព្រមពីមហាសន្និបាតអង្គការសហប្រជាជាតិ និងត្រូវផ្ដល់សច្ចាប័នដោយព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ក្នុងការទទួលបានការផ្ដល់សច្ចាប័ននេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

## មាត្រា ៥

## ការអនុវត្តនៅកម្ពុជា

កិច្ចព្រមព្រៀងបន្ថែមនេះត្រូវអនុវត្តជាច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ក្រោយពេលផ្តល់សច្ចាប័នទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃច្បាប់ផ្ទៃក្នុងរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញា។

## មាត្រា ៦

## ការចូលជាធរមាន

កិច្ចព្រមព្រៀងបន្ថែមនេះ ត្រូវចូលជាធរមាននៅថ្ងៃដែលភាគីទាំងពីរបានជូនដំណឹងគ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា លក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់សម្រាប់ការចូលជាធរមាន ត្រូវបានបំពេញរួចរាល់។

ធ្វើនៅទីក្រុងញូវយ៉ក និងរាជធានីភ្នំពេញ នាថ្ងៃទី១១ខែសីហាឆ្នាំ២០២១ និងថ្ងៃទី២៦ ខែសីហាឆ្នាំ២០២១ជាបន្តបន្ទាប់ ជាពីរច្បាប់ដើមជាភាសាអង់គ្លេសនិងភាសាខ្មែរ។ ក្នុងករណីមានភាពខុសគ្នា ភាសាអង់គ្លេសត្រូវយកជាភាសាគោល។

**តំណាងរាជរដ្ឋាភិបាលកម្ពុជា**

**ប៊ិន ឈិន**
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**តំណាងអង្គការសហប្រជាជាតិ**

**មីហ្គេល ដឺសែរ៉ា សូអារ៉េស**
អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់
និងជាអ្នកច្បាប់របស់ អ.ស.ប.

# ឧបសម្ព័ន្ធ ២
# ការចូលរួមចំណែកជាគំនិត

ដេវីដ សេវហ្វឺ (David Scheffer)
មជ្ឈមណ្ឌលឯកសារកម្ពុជា
ជី អាយ ស្សិត (GIZ)
ហេឡេន ចាវីស (Helen Javis)
អង្គការក្ដីករុណា
សាកលវិទ្យាល័យឡាត្រូប (La Trobe)
សហាមេធាវីនាំមុខ (តំណាងដើមបណ្ដឹងរដ្ឋប្បវេណី)
មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់
ម៉ារី វិលម៉ិត (Marie Wilmet)
ណាថាន ជេ. ឆាន (Nathan J. Chan)
រីដ្រេស (REDRESS)
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
សឹម សុរិយ៉ា
អង្គការចិត្តសង្គម អន្តរវប្បធម៌
សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង
អង្គភាពគាំពារជនរងគ្រោះ (អ.វ.គ.ក)
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (អ.វ.គ.ក)
អង្គការនារីដើម្បីសន្តិភាព (Women Peace Makers)
អង្គការយុវសន្តិភាព (Youth for Peace)
អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)

សូមស្កេន ដើម្បីចូលអាន សេចក្ដីអំពាវនាវរបស់សហចៅក្រមរបាយការណ៍ឱ្យមានការចូលរួមជាគំនិត និង គំនិតទាំងឡាយដែលទទួលបាន ។